ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

មាគមបុគ្គលិកសិក្សាខ្មែរ

# ទស្សនាវដ្ដី

**១៣**

# គ្រូបង្រៀន



ខែ តុលា - វិច្ឆិកា - ធ្នូ ឆ្នាំ ២០០០

ផ្សាយចេញរាល់ត្រីមាស ពីទីចាត់ការសមាគមបុគ្គលិកសិក្សាខ្មែរ
១២៨ មហាវិថីព្រះនរោត្តម (ភ្នំពេញ)
ទូរស័ព្ទ : ០២៣ ២១៦ ១៨៤
០១២ ៩៣១ ២០២
០១៥ ៩១៨ ១២៤

# មាតិកាអត្ថបទ

## វិចារណកថា

ទំព័រ

១- ពត៌មាន :

- លិខិតថ្លែងអំណរគុណ ........................................................ ១
- ប្រាសាទសម្បូរណ៍ព្រៃគុករឺ ព្យសានបុរៈ .................................. ២

២- វប្បធម៌ទូទៅ :

- អត្តសញ្ញាណវប្បធម៌ខ្មែរ ...................................................... ៤
- រៀនវាក្យសព្ទ ...................................................................... ៧
- បេតិកភណ្ឌ (អត្ថបទបកប្រែ) ............................................... ៨
- អច្ឆរិយវត្ថុទាំងប្រាំពីរនៃសកលលោក ..................................... ១០
- អាថ៌កំបាំងនៃឈ្មោះភូមិស្រុក (តពីទស្សនាវដ្ដីលេខ ១១) .......... ១២
- អង្គ ..................................................................................... ១៣
- ការបំភ្លឺមតិ .......................................................................... ២៣
- ប្រវត្តិកីឡា ម៉ារ៉ាតុង ............................................................ ២៤

៣- វិទ្យាសាស្ត្រអប់រំ :

- លក្ខណៈពិសេសរបស់វ៉ៃយជំទង់ (ត - ចប់) ............................. ២៦
- បច្ចេកទេសកសាងសំនួរ និង ការប្រត្តិបត្តិ ................................ ៣២
- ចំនួនប្រជារាស្ត្រក្នុងស្រុកនៅតាមខេត្តក្រុង (ត) ....................... ៣៧
- លោកគ្រូអ្នកគ្រូដឹងទេ ? ....................................................... ៤០

៤- វេចនិកាស្វែរង :

- " ត " ដាក់ស្រះ " ុ " ម្ដេចអានថា " តុក " .............................. ៤១
- ធ្វើដូចម្ដេចដើម្បីឈប់ជក់បារី .? ............................................ ៤២

៥- កំណាព្យ :

- ត្រី ក្អិត ក្អុក ក្អី ............................................................... ៤៤

៦- ករណីពិសេស (អក្ខរាវិរុទ្ធសារថ្មី) ........................................ ៤៥

គណៈកម្មការទទួលខុសត្រូវទស្សនាវដ្ដីគ្រូបង្រៀន

១- លោក យ៉ង់ ធី

២- លោក យស់ អ៊ាង

៣- លោក ជុំ ហ៊ិន

គណៈកម្មការនិពន្ធ

- សមាជិក - ជិកា ស, ប, ស, ខ

ក្របមុខ :

រូបតោនៅប្រាសាទសំបូរព្រៃគុក

# វិចារណកថា

ខ្ញុំតែងតែគិតមមៃជាប់ជានិច្ច ទៅលើការអប់រំនៅកម្ពុជា ទាំងនៅនាបច្ចុប្បន្ន និង ទាំងនៅពេលអនាគត។

យើងដឹងហើយថា ការអប់រំគឺជាភារកិច្ចរបស់យើងទាំងអស់គ្នា។ តែបច្ចុប្បន្នកាលនេះ ទាំងអស់គ្នានៅមើលស្រាលទៅលើការអប់រំ។ គ្រួសារ សាលារៀន សហគមន៍ ពុំបានព្រួតដៃគ្នាប្រយុទ្ធក្នុងការអប់រំកុលបុត្រ កុលធីតា។ ការស្រុតចុះសីលធម៌ ដែលនាំអោយមានការភ័យព្រួយចំពោះវាសនាអនាគតប្រទេស បានស្តែងឡើងយ៉ាងច្បាស់តាមរយៈបទល្មើស និង អំពើអនាធិបតេយ្យគ្រប់បែបយ៉ាង ដែលសង្គមសព្វថ្ងៃកំពុងជួបប្រទះ ដូចជាអំពើឃាតកម្ម ចោរកម្ម ការចាប់ជំរិតយកប្រាក់ ការរំលោភខាងផ្លូវភេទ និង ការជួញដូរស្ត្រីភេទ និងកុមារ-ល-។ នេះជាបញ្ហាទី១ ដែលកំពុងចោទសព្វថ្ងៃ ហើយជាបញ្ហាស្រួចស្រាលបំផុត។ គេនាំគ្នាស្រែក តែសកម្មភាពអប់រំមិនមាន។ គេប្រគល់ភារកិច្ចលុបបំបាត់អំពើអនាធិបតេយ្យខាងលើ តែទៅលើនគរបាល និង រាជអាវុធហត្ថប៉ុននោះ។ រីឯបញ្ហាទីពីរ គឺការបណ្តុះបណ្តាលធនធានមនុស្សតាមរយៈគ្រឹះស្ថានសិក្សា គឺ ÷

1/- អប់រំមនុស្ស អោយបានជាមនុស្សល្អ ប្រកបដោយសីលធម៌

2/- អប់រំមនុស្ស អោយក្លាយជាពលរដ្ឋមានចំនេះដឹងជ្រៅជ្រះ ចេះគិតពិចារណា ចេះវិនិច្ឆ័យរកខុសត្រូវ

3/- ជាពលករ មានមុខរបរអាចចិញ្ចឹមជីវិតបាន និង មានសមត្ថភាពការងារបរិបូរសមរម្យ។

« ការអភិវឌ្ឍន៍ធនធានមនុស្ស គឺ ការកសាងធនធានមនុស្សប្រកបដោយសុខភាពមាំមួន មានចំនេះវិជ្ជា និងវប្បធម៌ខ្ពង់ខ្ពស់ មានឥរិយាបថថ្លៃថ្នូរ ស្អាតស្អំ មានស្មារតីទទួលខុសត្រូវ មានគំនិតសម្មាអាជីវោ មានមហិច្ឆតាការងារមោះមុត ដើម្បីទទួលផ្លែផ្កាស្នាដៃរបស់ខ្លួន រំដោះខ្លួនចេញពីភាពក្រីក្រ និង ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍន៍ប្រទេសជាតិទាំងមូល [1] »

បច្ចុប្បន្នកាលនេះ រាជរដ្ឋាភិបាលមានគោលនយោបាយស្តីពីការអប់រំ និងយុទ្ធសាស្ត្រមួយសមស្រប និងមានកម្មវិធីសិក្សាមួយថ្មី និងសៀវភៅសិក្សាថ្នាក់បឋមដល់មធ្យមសិក្សា។ ថ្មីៗនេះ ក្រសួង អ.យ.ក បានពិភាក្សាពីផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ 2001- 2005 និងបានកំនត់គោលដៅនៃផែនការដែលមាន 4 ចំនុចគឺ ÷

---

[1] ដកស្រង់ចេញពីកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលពីឆ្នាំ ១៩៩៨ ដល់ឆ្នាំ ២០០៣។

1/- ធ្វើយ៉ាងណាសំរេចទិសដៅអប់រំមូលដ្ឋានសំរាប់ទាំងអស់គ្នាអោយបាននៅអំឡុងឆ្នាំ 2010 ។

2/- កម្មវិធីយុទ្ធសាស្ត្រជាអាទិភាព ត្រូវធ្វើតាមរយៈយន្តការរបស់កម្មវិធីសកម្មភាពជាអាទិភាព (P.A.P) ដោយផ្តល់ថវិកា សំរាប់ដំណើរការទៅអោយសាលារៀន និង គ្រឹះស្ថានឧត្តមសិក្សា និង បណ្តុះបណ្តាលបច្ចេកទេស វិជ្ជាជីវៈ ។

3/- ផ្តោតការយកចិត្តទុកដាក់ទៅដល់ការលើកកំពស់ប្រសិទ្ធភាពសេវាកម្មបង្រៀន គឺត្រូវបង្កើនអត្រាឡើងថ្នាក់នៅសាលាបឋមសិក្សា និង ការបង្កើនអត្រាឆ្លងភូមិសិក្សាពីបឋមទៅមធ្យមសិក្សា ។

4/- តំរូវការសំភារៈបរិក្ខារបន្ថែមទៀត ពិសេសនៅមធ្យមសិក្សា ។ ផែនការសាងសង់បន្ទប់រៀន ពី 15 000 ទៅ 20 000 បន្ទប់ ក្នុងរយៈពេល 5 ឆ្នាំខាងមុខ ត្រូវបានបញ្ចូលក្នុងផែនការយុទ្ធសាស្ត្រនេះដែរ ។

ដូចនេះយើងសង្ឃឹមថាយុទ្ធសាស្ត្រទាំង4ចំនុច ដែលជាអាទិភាពសំរាប់ធ្វើការកែទំរង់គោលនយោបាយ និង យុទ្ធសាស្ត្រនៃវិស័យអប់រំ នឹងត្រូវបានអនុវត្តចាប់ពីឆ្នាំ 2001 នេះតទៅ ។

សូមជំរាបផងដែរថា ប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍យើងនេះ ក្រោយពីវិបត្តិសេដ្ឋកិច្ច ឆ្នាំ 1997 បានភ្ញាក់រលឹកនឹកដល់ប្រព័ន្ធអប់រំ ។ ប្រទេសថៃ ម៉ាឡេស៊ី ឥណ្ឌូណេស៊ី និង សិង្ហបុរី បានពង្រឹងប្រពន្ធ័អប់រំរបស់ខ្លួន ដោយយល់ឃើញថា សេដ្ឋកិច្ចរឹងប៉ឹងបានដោយសារមនុស្សមានសមត្ថភាព និង យកចំនេះដឹង ចំនេះធ្វើ ទៅចូលរួមក្នុងវិស័យសេដ្ឋកិច្ច ។ ប្រទេសទាំងនេះ បានស៊ើរើប្រពន្ធ័អប់រំរៀងៗខ្លួន ស្របតាមគោលនយោបាយថ្មីដែលមានគោលបំនងចង់បានមនុស្សមានប្រាជ្ញាភ្លឺថ្លា ប្រកបដោយវិចារណញ្ញាណ និង មានសមត្ថភាពពេញលេញ [1] ។

នៅប្រទេសកម្ពុជាយើងវិញ ពិតមែនតែមិនទាន់មានច្បាប់ស្តីពីការអប់រំជាតិនៅឡើយក៏ដោយចុះ ក៏ប៉ុន្តែយើងមានកម្មវិធីសិក្សាមួយថ្មី ទាំងខាងផ្នែកវិទ្យាសាស្ត្រពិត និង ផ្នែកសិក្សាសង្គម ។ កម្មវិធីសិក្សាថ្មី ទាមទារអនុវត្តអោយបានស៊ីជំរៅ ស្របតាមខ្លឹមសារអប់រំ និង តាមការណែនាំគរុកោសល្យនៃអ្នកផលិតកម្មវិធី ។

ជារួម ដើម្បីដោះស្រាយអោយបានជោគជ័យនូវបញ្ហាទាំងពីរ គឺ ÷ សីលធម៌ និងការបណ្តុះបណ្តាលធនធានមនុស្សដែលខ្ញុំបានជូនជ្រាបរួចហើយនោះ យើងត្រូវប្តេជ្ញាចិត្តថា ការអប់រំ ជាភារកិច្ចយើងទាំងអស់គ្នា ។ គ្រួសារ សាលារៀន និងសហគមន៍ ត្រូវតែពួតដៃគ្នាធ្វើការប្រយុទ្ធរួមក្នុងវិស័យអប់រំដើម្បីអភិវឌ្ឍ ។ មនុស្សមិនមានគុណភាព និងប្រសិទ្ធភាពក្នុងការងារប្រចាំថ្ងៃ និង មិនមានសីលធម៌រស់នៅល្អ មិនមែនជាមនុស្សស្គាល់កាតព្វកិច្ចសង្គមវប្បធម៌របស់ខ្លួនឡើយ ។

យ៉ង់ ធី

---

[1] voir le Courrier de l'UNESCO mois Juillet /Août 1999




# លិខិតថ្លែងអំណរគុណ

* * * * * *

នាយកពុទ្ធសាសនបណ្ឌិត្យ សូមថ្លែងអំណរគុណដល់លោក **យ៉ិច ឌី** ប្រធានគណៈកម្មាធិការនាយកនៃបុគ្គលិកសិក្សាខ្មែរ ដែលបានធ្វើជាអំណោយសៀវភៅ **អក្ខសញ្ញាណប្រទេសកម្ពុជា** ចំនួន ១០ ក្បាល។

ខ្ញុំបាទមានកិត្តិយស ជំរាបលោកប្រធានថា អំណោយសៀវភៅ **អក្ខសញ្ញាណប្រទេសកម្ពុជា** នេះខ្ញុំបាទនឹង យកដាក់ក្នុងបណ្ណាល័យនៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ សំរាប់ជាប្រយោជន៍ដល់សិស្ស និស្សិត និងអ្នកស្រាវជ្រាវ ទូទៅ។ គុណប្រយោជន៍ដ៏ធំធេងនេះ ជាសក្ខីភាពមួយបញ្ជាក់ថា ការខិតខំប្រឹងប្រែងរបស់លោកទាំងកំលាំងកាយ និង កំលាំងចិត្ត ពិតជាគំរូដ៏ល្អសំរាប់កូនខ្មែរជំនាន់ក្រោយជាក់ជាមិនខាន។

សូមលោកប្រធានទទួល នូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ភ្នំពេញ ថ្ងៃទី 19 ខែ កុម្ភៈ ឆ្នាំ 2001

**ជ. នាយក**

ហត្ថលេខា និងត្រា

**ខៀវ បញ្ញាឧត្តម**

# ប្រាសាទសម្បូរណ៍ព្រៃគុក[1] វិញ្ញាសាលម្នុះ

* * * * * *

កាលពីថ្ងៃសៅរ៍ ទី ១៦ ខែមិថុនា ឆ្នាំ ២០០១ រួមដំណើរដោយលោក ស្វាយ ឋិត្យ លោក កៅ ឡឿន និង លោក ឈា ឈាន ខ្ញុំបានធ្វើដំណើរទៅខេត្តកំពង់ធំ ក្នុងគោលបំណងស្វែងយល់ពីប្រាសាទសម្បូរណ៍ព្រៃគុក ដើម្បីយកមកចុះផ្សាយតាមរយៈទស្សនាវដ្តីគ្រូបង្រៀន ។

លោក គិម ចិសុទ្ធ អនុប្រធានមន្ទីរ អ. យ. ក ខេត្តអមដោយលោក ម៉ុន សឿន និងលោក ឋិត្យ ណៃហ៊ាង សមាជិកគណៈកម្មាធិការ ស.ប.ស.ខ ខេត្តកំពង់ធំ បានទទួលយើងខ្ញុំដោយក្តីកក់ក្តៅ និង រីករាយជាទីបំផុត ហើយបានជូនដំណើរទៅទស្សនាប្រាសាទសម្បូរណ៍ព្រៃគុកដែលស្ថិតនៅចំងាយប្រហែល ៣៥ គីឡូម៉ែត្រពីទីរួមខេត្តកំពង់ធំ ។

ក្រុមប្រាសាទសម្បូរណ៍ព្រៃគុកមានប្រាសាទចំនួន ៥០ ធ្វើអំពីថ្ម និង ឥដ្ឋ ។ មួយភាគធំនៃប្រាសាទទាំងនេះត្រូវបានរលំបាត់រូប បាត់រាង ក្លាយជាដំបូក ដោយដើមឈើដុះពីលើ ។

ក្រុមប្រាសាទសម្បូរណ៍ព្រៃគុក ត្រូវបានសាងសង់ដោយព្រះមហាក្សត្រខ្មែរមួយព្រះអង្គព្រះនាម ឦសានវរ្ម័នរវាង គ. ស. ៦១៥ និង ៦៣៥ សតវត្សទី ៧ ដើម្បីសំរាប់ជារាជធានីផង និង ជាបូជនីយដ្ឋានឧទ្ទិសថ្វាយព្រះសិវៈផង ។

ប្រាសាទដែលយើងខ្ញុំបានទស្សនាមុនគេបង្អស់ គឺប្រាសាទនាគព័ន្ធ[2] ។ ប្រាសាទនាគពន្ធ័ស្ថិតនៅក្រុមប្រាសាទខាងត្បូងដែលមានកំពែងពទ្ធ័ជុំវិញពីរជាន់ ៖

ក- កំពែងទី ១ ៖ ខាងក្រៅមានបណ្តោយ ៣០៩ ម៉ែត្រ ទទឹង ២៧៤ ម៉ែត្រ និង មានគោបុរៈចូលទាំង បួនទិស ។

ខ- កំពែងទី ២ ៖ ខាងក្នុងធ្វើពីថ្ម និង មានចំលាក់ល្អៗ នៅលើថ្ម

គ- នៅលើទីធ្លាកំពែងទី ១ និង ទី ២ មានប្រាសាទតូចៗសង់ដោយឥដ្ឋរាយរាប់នៅក្នុងទីនោះ ។ ក្នុងចំណោមប្រាសាទទាំងនោះ គេឃើញមានប្រាសាទមួយដែលជាប្រាសាទមានរូប ៨ ជ្រុង ។

ក្រុមប្រាសាទមួយទៀតហៅថា "ប្រាសាទតោ" មានកំពែងព័ទ្ធជុំវិញមានបណ្តោយ ៣២៨ ម៉ែត្រ ទទឹង ៣១០ម៉ែត្រ[3] នៅចំកណ្តាលកំពែងមានប្រាសាទមួយឈ្មោះ "ប្រាសាទតោ" មានជណ្តើរ និង ទ្វារចូលពីខាងកើត ។ រីឯទ្វាបីទៀតជាទ្វាបញ្ឆោត ។ នៅក្បាលជណ្តើរទាំងបួនទិសមានរូបតោពីររាងមាំអង្គុយអើតក្បាល និង មានរោម

---

(1) ឯកសារខ្លះសរសេរ ព្រៃគុហ៍ ខ្លះសរសេរព្រៃគុក ។

(2) អ្នកខ្លះអោយឈ្មោះថាប្រាសាទយាយពាន់

(3) អំពីចំនួនប្រាសាទ និង ទំហំនៃកំពែងព័ទ្ធជុំវិញ ឯកសារនិយាយខុសគ្នាទាំងអស់

# វប្បធម៌ខ្មែរ



# អត្តសញ្ញាណវប្បធម៌ខ្មែរ

## L'Identité Culturelle Khmère

វប្បធម៌ ជាលក្ខណៈសារវន្ត និង អចិន្ត្រៃយ៍ និង ជាសមាសភាគមួយនៃអត្តសញ្ញាណជាតិ ។ បានសេចក្ដីថា ជាតិនីមួយៗ មានវប្បធម៌របស់ខ្លួនជាលក្ខណៈសំគាល់ ។

ជាបន្ទាប់ទៅនេះ ខ្ញុំសូមលើកយកអត្តសញ្ញាណវប្បធម៌ខ្មែរមកជំរាប ដោយមានបំណងចង់អោយអស់លោកជាអ្នកបង្រៀនសិស្សយល់ច្បាស់ ដើម្បីចៀសវាងការភ័ន្តច្រឡំបង្រៀនអត្តសញ្ញាណវប្បធម៌ខ្មែរថា ជាអត្តសញ្ញាណជាតិទៅវិញ [1] ។

អស់លោកបានរៀនចេះចាំអស់ហើយអំពីវប្បធម៌ និង អរិយធម៌ខ្មែរ ។ ក៏ប៉ុន្តែ អស់លោកមិនបានគិតពិចារណាអោយបានយល់ដឹងពីអត្តសញ្ញាណវប្បធម៌ខ្មែរឡើយ ។ ដើម្បីបំបាត់ភាពស្រពេចស្រពិលរបស់អស់លោក ខ្ញុំសូមជ្រាបជាមុនសិនថា កេរមរតកវប្បធម៌ រឺ បេតិកភណ្ឌវប្បធម៌ ដែលបុព្វបុរសខ្មែរបានទុកអោយកូនចៅជំនាន់ក្រោយនៅពាសពេញប្រទេសសព្វថ្ងៃនេះ មានពីរ (២) ចំណែក តែនៅជាប់ជាមួយគ្នា មិនអាចបំបែកចេញពីគ្នាបានឡើយ ។

១- បេតិកភណ្ឌដែលមានរូប (patrimoine matériel) រឺអាចស្ទាបបាន (patrimoine tangible) ។

២- បេតិកភណ្ឌមិនមានរូប (patrimoine immatériel) រឺមិនអាចស្ទាបបាន ប៉ះពាល់បាន (patrimoine intangible) រឺបេតិកភណ្ឌគំនិត បញ្ញា (patrimoine spirituel) ។

«On ne peut dissocier le patrimoine materiel et le patrimoine immateriel car ils sont appelés l'un et l'autre à constituer la culture de l'avenir» .

ខ្ញុំសូមលើកឧទាហរណ៍ពីរមកបញ្ជាក់ :

១- ប្រាសាទអង្គរវត្ត និង ប្រាសាទបាយ័នមានតួប្រាសាទ ជាក់ស្ដែងមានរូបមានរាង តែគំនិត រឺ ប្រាជ្ញាញាណនៃស្ថាបត្យករសម័យអង្គរ យើងមិនអាចឃើញបានទេ ។ ហេតុអ្វីបានជាព្រះបាទ សុរិយាវរ្ម័នទី២ សាងអង្គរវត្ត និង ព្រះបាទជ័យវរ្ម័នទី៧ សាងប្រាសាទបាយ័ន ។ អ្នកមិនចេះ មិនដឹងឃើញតែដុំថ្មបន្តុបលើគ្នា និង តួប្រាសាទ ប៉ុណ្ណោះ ។ រីឯសំណង់នេះវិញ មិនដឹងជាស្ថាបនាសំរាប់អ្វី ? ហេតុអ្វីបានជាមានកំពូលប្រាំ ? ហេតុអ្វីបានជាមាន មុខបួន ? ។

(1) សូមអានទស្សនាវដ្ដីគ្រូបង្រៀនលេខ ១១ និង សៀវភៅអត្តសញ្ញាណប្រទេសកម្ពុជា ។

ខេមរនីយកម្ម ។

ភាសាអំបូរមន-ខ្មែរ ដែលមាននៅលើទឹកដីកម្ពុជាសព្វថ្ងៃ ត្រូវបានរក្សាទុកដដែល ដូចជាភាសាគួយ ព្នង ស្ទៀង -ល- ។

៣- **អក្សរ**

ពិតមែនតែអក្សរខ្មែរមានប្រភព និងលំនាំចេញពីឥណ្ឌាខាងត្បូងយ៉ាងណាក៏ដោយ ក៏ខ្មែរបានច្នៃអោយបានសមសួន ព្រមទាំងមានក្បួនខ្នាតច្បាស់លាស់ ។

៤- **អក្សរសិល្ប៍**

មានតាំងពីមុនសម័យអង្គរ ។ សិលាចារឹកសរសេរជាភាសាខ្មែរបូរាណ ជាពាក្យរាយមានតាំងពី ស.វ ទី៧ ។ សិលាចារឹកចាស់ជាងគេ គឺ សិលាចារឹកអង្គរបុរី (គ.ស ៦១១) ។

អក្សរសិល្ប៍នៅសម័យអង្គរ ច្រើនប្រើភាសាសំស្ក្រឹត ។ ដូចនេះការផ្សព្វផ្សាយមិនបានទៅដល់គ្រប់មជ្ឈដ្ឋានឡើយ ។

អក្សរសិល្ប៍សម័យក្រោយអង្គរ មានការរីកលូតលាស់ និងបានផ្សព្វផ្សាយជ្រួតជ្រាបដល់ប្រជាជន តាមរយៈវត្តអារាម ។ ចំពោះរឿងព្រេង រឿងនិទានអ្នកស្រុកបានស្ដាប់ បានយល់យ៉ាងស្រួល ។

អក្សរសិល្ប៍សម័យទំនើប ក្រោមអាណាព្យាបាលបារាំង មិនមានការរីកចំរើនទេ ។ តែក្រោយឆ្នាំ១៩៥៣ អ្នកនិពន្ធមានសេរីភាពក្នុងការនិពន្ធ ហើយបានបញ្ចេញស្នាដៃគួរជាទីពេញចិត្ត ។

៥- **សិល្បៈ**

មានច្រើនប្រភេទ ដូចជាសិល្បៈរបាំ ចំរៀង ភ្លេង ល្ខោន គំនូរ សំណង់ សូន្យរូបជាដើម ។ សូមស្វែងយល់ពីប្រភេទនីមួយៗ តាមឯកសារ ។

៦- **ជំនឿ ទំនៀមទំលាប់ ប្រពៃណី**

ជំនឿសាសនា មានឥទ្ធិពលទៅលើប្រពៃណី ទំនៀម ទំលាប់ ។ ពិធីផ្សេងៗ ដែលមានតាំងពីកើត រហូតដល់ស្លាប់ដូចជា បង្កក់កូន កោរជុក ចូលម្លប់ ភ្ជាប់ពាក្យ ស្ដីដណ្ដឹង អាពាហ៍ពិពាហ៍ ឡើងផ្ទះ -ល- បានបាត់បន្តិចម្ដងៗ ក្នុងរបៀបចាត់ចែងពិធី ។ ក៏ប៉ុន្តែ ពិធីបុណ្យសាសនាមានបុណ្យចូលឆ្នាំ ភ្ជុំបិណ្ឌ បុណ្យកឋិនទាន បុណ្យផ្កា ចូលវស្សា ចេញវស្សា បំបួសនាគ -ល- នៅមានឥទ្ធិពល និងត្រូវបានខ្មែរយើងអនុវត្តស្របតាមគន្លងទំនៀមទំលាប់ ប្រពៃណីរបស់ជាតិ ។

**អរិយធម៌ខ្មែរ វិវឌ្ឍតាមកត្តាវប្បធម៌ទាំង ៦ ខាងលើនេះ ចាត់ទុកជាអត្តសញ្ញាណវប្បធម៌ខ្មែរ** (1)

អត្ថបទរៀបរៀងដោយ **លោក យង់ ធី**

ទទួលមតិគាំទ្រពីលោកព្រឹទ្ធាចារ្យ **ឡេង ង៉ុន**

(1) សូមអានទស្សនាវដ្ដីគ្រូបង្រៀនលេខ ៩ ទំព័រ ៤៥ ។

# រៀនពាក្យស័ព្ទ

ខ្ញុំលើកយកពាក្យមួយដែលលោកអាឡាំង[1] អោយនិយមន័យប្លែកពីការចេះដឹងរបស់យើងទាំងអស់គ្នាកន្លងមក។ ពាក្យនោះគឺពាក្យ âme ដែលយើងធ្លាប់ចេះដឹងមកថាអាត្ម័ន រឺ ព្រលឹង ប្រើក្នុងវិស័យវប្បធម៌ ។ ឧ. "វប្បធម៌ជាព្រលឹងនៃប្រជាជាតិ "។ ឥឡូវនេះសូមលោកគ្រូ-អ្នកគ្រូរៀនពាក្យ âme ដែលមានន័យផ្សេងពីព្រលឹង។ âme មានន័យមួយទៀតគឺចិត្ត។

<u>ពាក្យគោរព្ភៈ</u> អាត្ម័នអាត្មា ទោះប្រើពាក្យណា ក៏បានដូចគ្នា ទាំងពាក្យអត្តា នេះឯងក៏ជាពាក្យមានន័យថា ចិត្ត ឬ ខ្លួនប្រាណ[2]។

លោកអាឡាំងអោយនិយមន័យពាក្យ âme ដូចខាងក្រោម។ ខ្ញុំសូមភ្ជាប់អត្ថបទជាភាសាបារាំងដើម្បីអោយអស់លោកអ្នកចេះភាសានេះអានបន្ថែម ពីព្រោះការបកប្រែពីភាសាមួយទៅភាសាមួយទៀតមិនបានល្អដូចភាសាដើមរបស់អ្នកនិពន្ធឡើយ។

## L'ÂME

L'âme, c'est ce qui refuse le corps. Par exemple ce qui refuse de fuir quand le corps tremble, ce qui refuse de frapper quand le corps s'irrite, ce qui refuse de boire quand le corps a soif, ce qui refuse de prendre quand le corps désire, ce qui refuse d'abandonner quand le corps a horreur. Ces refus sont des faits de l'homme. Le total refus est la sainteté; l'examen avant de suivre est la sagesse; et cette force de refus c'est l'âme. Le fou n'a aucune force de refus; il n'a plus d'âme. On dit aussi qu'il n'a plus conscience et c'est vrai. Qui cède absolument à son corps soit pour frapper, soit pour fuir, soit seulement pour parler, ne sait plus ce qu'il fait ni ce qu'il dit. On ne prend conscience que par une opposition de soi à soi.
Exemple : Alexandre à la traversée d'un désert reçoit un casque plein d'eau; il remercie et le verse par terre devant toute l'armée. Magnanimité; âme, c'est-à-dire grand âme. Il n'y a point d'âme vile; mais seulement on manque d'âme. Ce beau mot ne désigne nullement un être, mais toujours une action.

**Alain, *Définitions***

## ចិត្ត

ចិត្តគឺអ្វីដែលមិនព្រមស្របតាមខ្លួនប្រាណ។ ឧទាហរណ៍ អ្វីដែលឃាត់មិនអោយរត់ កាលណាខ្លួនកំពុងភ័យញ័ររន្ធត់ អ្វីដែលឃាត់មិនអោយវាយ កាលណាខ្លួនមួម៉ៅ ក្តៅក្រហាយ អ្វីដែលឃាត់មិនអោយផឹក កាលណាខ្លួនស្រេក អ្វីដែលឃាត់មិនអោយកាន់យក កាលណាខ្លួនប្រាថ្នាចង់បាន អ្វីដែលឃាត់មិនអោយបោះបង់ចោល កាលណាខ្លួនខ្ពើមរអើមជាខ្លាំង។ ការមិនធ្វើតាមខ្លួនទាំងអស់នេះហើយ ជាអំពើរបស់មនុស្ស។ ការមិន

(1) Emile Chartier ហៅ Alain (1868-1951) ជាទស្សនវិទូបារាំងដ៏ល្បីល្បាញម្នាក់។ គាត់បង្រៀននៅវិទ្យាល័យ Henri IV និង ជាអ្នកនិពន្ធសៀវភៅ។

(2) ដកស្រង់ចេញពីវចនានុក្រមខ្មែរទំព័រ ១៧២៧។

ព្រម ទាំងស្រុងជាសន្តភាព[1] ។ ការពិនិត្យពិច័យមុននឹងធ្វើតាម គឺជាគតិបណ្ឌិត ហើយកំលាំងដែលទប់មិនព្រមតាម គឺ ចិត្ត[2] ។ មនុស្សឆ្កួត មិនមានកំលាំងទប់សោះឡើយ។ ដូចនេះ វាមិនមានចិត្ត។ គេពោលដែរថា វាលែងមានសម្បជញ្ញៈ ទៀតហើយ។ នេះជាការពិត។ នរជនណាដែលទប់ទល់មិនបានទាល់តែសោះ ទៅនឹងខ្លួនដែលចង់វាយគេ ចង់រត់ រឺមួយគ្រាន់តែចង់ និយាយស្តីប៉ុននោះ លែងដឹងថាខ្លួនធ្វើអ្វី រឺ និយាយអ្វី។ គេនៅមានសម្បជញ្ញៈ លុះត្រាតែមានការតទល់រវាងចិត្ត និង ខ្លួន។ ឧទាហរណ៍ អាឡេចសង់ (Alexandre)[3] នៅពេលធ្វើដំណើរ ឆ្លងកាត់វាលខ្សាច់មួយ បានទទួលមួកដែកមួយពេញដោយទឹក។ គាត់ថ្លែងអំណរគុណ ហើយចាក់ទឹកចោល នៅមុខកងទ័ព។ នេះជាមហាស្រ័យភាព[4] នេះជាចិត្តរឹង មហារឹង។ ចិត្តអប្រីយ៍មិនមានទាល់តែសោះ ប៉ុន្តែគ្រាន់តែអត់ចិត្តប៉ុននោះ។ ពាក្យដ៏ល្អនេះមិនចង្អុលបង្ហាញមនុស្សទេ ក៏ប៉ុន្តែបង្ហាញអំពើជាដរាប។

**Alain *Définitions***

# បេតិកភណ្ឌ (អត្ថបទបកប្រែ)

**<< Le patrimoine du pays est par essence son identité culturelle, et qu'il soit grand ou petit, majestueux ou simple, matériel ou immatériel, il doit être conservé et avoir une signification pour toutes les générations futures >>**

**I.M. Pei**
*architecte américain (1917)*

<< តាមអត្ថន័យ បេតិកភណ្ឌរបស់ប្រទេស ជាអត្តសញ្ញាណវប្បធម៌នៃប្រទេសនោះ ទោះតូច រឺ ធំស្កឹមស្កៃ រឺ សាមញ្ញ រូបី រឺ អរូបីយ៉ាងណាក៏ដោយ ក៏ត្រូវតែថែរក្សាអោយបានគង់វង្ស និង ត្រូវអោយអ្នកជំនាន់ក្រោយបានយល់ដឹង ជ្រួតជ្រាបពីអត្ថន័យនៃបេតិកភណ្ឌនោះ ។ >>

---

(1) ភាពបរិសុទ្ធ

(2) ចិត្តរឹងមិនទន់តាម

(3) Alexandre le Grand ហេតុអ្វីបានជាគាត់ចាក់ទឹកចោល ?

ពីព្រោះ ទី១- ចិត្តរឹងយកឈ្នះលើសំរេកជាខ្លាំងនៅលើវាលខ្សាច់

ទី២- កងទ័ពដែលកំពុងតែស្រេកជាខ្លាំងដូចស្តេចដែរនោះមុខជាអាក់អន់ចិត្ត ហើយវាយតំលៃទៅលើទង្វើរបស់ស្តេច Alexandre le Grand

(4) ចិត្តដ៏ប្រសើរ

# LA MÉMOIRE N'EST PAS QUE DE PIERRE

Le patrimoine mondial ne se réduit pas aux seuls monuments que l'Homme a érigés. Les valeurs qui s'attachent à la mémoire des peuples , plus impalpables que les pierres, ne sont pas les moins précieuses.

Léon Pressouyre
*(dans le Courrier UNESCO mois Décembre 2000)*

## លំនឹក (ការចងចាំ) មិនមែនកើតមានមកតែអំពីថ្មប៉ុណ្ណោះទេ[1]

បេតិកភណ្ឌពិភពលោក មិនត្រឹមតែជាបូជនីយស្ថានដែលមនុស្សលោកបានសាងសង់ប៉ុណ្ណោះទេ ។ តំលៃដែលជិតជាប់ទៅនឹងការចងចាំមិនភ្លេចនៃប្រជារាស្ត្រ ហើយដែលស្ទាបរីចាប់មិនបាននោះមានតំលៃថ្លៃដូចថ្មដែរ ។

**<u>ការបកស្រាយបំភ្លឺមតិខាងលើដើម្បីងាយយល់</u>**

ជាយូរយារមកហើយ សកលលោកចាប់អារម្មណ៍តែទៅលើប្រាសាទបូរាណ ដែលបុព្វបុរសបានសាងសង់ជាកេរមរតកទុកអោយកូនចៅជំនាន់ក្រោយ ដែលយើងរាល់គ្នាហៅថាបេតិកភណ្ឌ (patrimoine) ។

នាបច្ចុប្បន្នកាលនេះ គឺទើបតែប៉ុន្មានឆ្នាំកន្លងទៅនេះ ទស្សនៈដ៏ចង្អៀតនៃបស្ចិមប្រទេសពីរឿងបេតិកភណ្ឌបានត្រូវបែកធ្លាយ ។ តាមទស្សនៈថ្មីនៃអ្នកនិពន្ធ កវី និង អ្នកវប្បធម៌បានពន្យល់ថាបេតិកភណ្ឌជាតិ រឺ ពិភពលោក មិនត្រូវផ្តោតតែទៅលើប្រាង្គប្រាសាទប៉ុណ្ណោះទេ គឺត្រូវរាប់បញ្ចូល :

1- ទេសភាពល្អៗ ដែលចង្អុលបង្ហាញពីអន្តរកម្មរវាងមនុស្ស និង ធម្មជាតិ

2- បេតិកភណ្ឌដែលជាអរូបិ ស្ទាបកាន់មិនបាន គឺវាស្ថិតនៅលើស្មារតី និង គំនិត។ បេតិកភណ្ឌរូបិ និង អរូបិរួមគ្នាលេចចេញមកពីជំនឿ ពីរឿងនិទាន ពីទំនៀមទំលាប់ ពីអាកប្បកិរិយាដែលកើតចេញពីភាពប្លែកៗគ្នានៃប្រជាជាតិនីមួយៗ។

ដើម្បីអោយយល់កាន់តែច្បាស់ថែមទៀត ខ្ញុំសូមជូនឧទាហរណ៍ដូចតទៅ :

នៅប្រទេសកម្ពុជាយើងប្រាង្គប្រាសាទ និង រមណីយដ្ឋានត្រូវបានចាត់ទុកជាបេតិកភណ្ឌជាតិ ដូចជាប្រាសាទអង្គរវត្ត ប្រាសាទបាយ័ន ប្រាសាទតាព្រហ្ម-ល- ។

ក្រៅពីនេះ ភ្នំឧត្តុង្គ ភ្នំតូលែន ក្បាលស្ពាន[1] ភ្នំបូកគោ ភ្នំគិរីរម្យ ព្រះវិហារសសរមួយរយ និង ភ្នំសំបុក (ខេត្តក្រចេះ) បឹងទន្លេសាប ភ្នំក្រវាញ បារាយណ៍ទឹកថ្លា ត្រូវបានចាត់ទុកជាបេតិកភណ្ឌធម្មជាតិ និង វប្បធម៌ ។

ប្រាង្គប្រាសាទ និង រម្មណីយដ្ឋានដ៏ច្រើនខាងលើនេះដែលរាប់មិនទាន់អស់នៅឡើយនោះ ជាដុំថ្ម ជាភ្នំ ជាព្រៃព្រឹក្សា សរុបមកជារបស់មានរូប ( matériel) ។ ទស្សនៈពិភពលោកសព្វថ្ងៃ ភ្ជាប់របស់ឥតរូបដែលស្ទាបមិនបាន មើលមិនឃើញ (immatériel ou intangible ) ទាំងអស់នោះជា បេតិកភណ្ឌដែរ។

---

[1] គឺមិនមានតែនៅលើរបស់អ្វីដែលឃើញនោះទេ

[1] រមណីដ្ឋានក្បាលស្ពាន ជាស្ទឹងនៅខេត្តសៀមរាប ដែលមានឆ្លាក់លិង្គរាប់ 1000 នៅនឹងថ្មបាតស្ទឹង (Rivière aux mille lingas )

គេអោយឈ្មោះថាជាបេតិកភណ្ឌអំនិត រឺ ស្មារតី (patrimoine spirituel ) ។ ខ្ញុំសូមលើកយកឧទាហរណ៍មួយមកជំរាបតទៅទៀត ។ រមណីយដ្ឋានក្បាលស្ពានជាស្ទឹងដែលមានទឹកហូរធ្លាក់ពីភ្នំ ។ នៅខាងក្រោមក្បាលស្ពានបុព្វបុរសមិនដឹងជាធ្វើយ៉ាងណា ទើបអាចឆ្លាក់បានឧមាយោនី និងសិវលិង្គនៅជាប់នឹងថ្មតាមបណ្ដោយបាតស្ទឹងប្រវែងប្រហែល ២០០ម ។ ស្ទឹងនេះគេអោយ ឈ្មោះថា ស្ទឹងលិង្គមួយពាន់ (1000) "Rivière aux mille lingas" ។ យើងគួរសួរសួរក៏រសគល់ថា ហេតុអ្វីបានជាបុព្វបុរសខ្មែរឆ្លាក់រូបលិង្គ និង យោនីនៅបាតស្ទឹងដូចនេះ ? ចំលើយមានតែមួយ គឺមកពីជំនឿលើលទ្ធិព្រាហ្មណ្ឌសាសនាដែលយកលិង្គព្រះឥសូរ រឺ សិវលិង្គ និង ឧមាយោនីជាទីសក្ការៈបូជា ។ ទឹកស្ទឹងដែលហូរកាត់ សីវលិង្គ និង ឧមាយោនី ជាទឹកមន្ត អាចផ្ដល់នូវសិរីសួស្ដី ជ័យមង្គលគ្រប់បែបយ៉ាងដល់នរជនណាដែលបានផឹកបានងូត ។ សរុបសេចក្ដីមក បេតិកភណ្ឌរូបី និង អរូបីមានតំលៃស្មើគ្នាដូចលោក Léon Pressouyre [2] មានប្រសាសន៍ខាងលើនេះស្រាប់ ។

យ៉ង់ ធី

# អច្ឆរិយវត្ថុទាំងប្រាំពីរនៃសកលលោក

## Les Sept Merveilles du monde

*****************

អ្នកចេះដឹងខ្មែរយើងមួយចំនួន បានពោលថាប្រាសាទអង្គរវត្តជាអច្ឆរិយវត្ថុទី៧ នៃសាកលលោក ។ អ្នកពោលនោះ ប្រហែលជាបានឮត១គ្នាមកតែប៉ុណ្ណោះ ។ ឥឡូវនេះខ្ញុំសូមជំរាបលោកគ្រូ-អ្នកគ្រូពីចំនាត់ថ្នាក់អច្ឆរិយវត្ថុដែលសាកលលោកបានដឹង បានឮគ្រប់គ្នា តែអច្ឆរិយវត្ថុទាំងប្រាំពីរនោះរលាយរលត់បាត់ស្រមោលអស់ទៅហើយ ។ សព្វថ្ងៃនេះ នៅសល់តែពីរ៉ាមីតនៃប្រទេសអេស៊ីបប៉ុណ្ណោះ ។

១- ចេតិយនៃប្រទេសអេស៊ីប Les pyramides d'Egypte.

២- ឧទ្យានយោល រឺ ព្យួររបស់ព្រះរាជិនី សេមីរាមិសដែលមានព្រះនាមល្បីល្បាញនៃប្រទេសអាស្ស៊ីរី ។
ព្រះនាងទ្រង់ជាព្រះអគ្គមហេសីនៃព្រះបាទ នីណូស ។
Les jardins suspendus de Sémiramis à Barbylone.

3- បដិមាករធ្វើពីមាស និង ភ្លុកនៃព្រះអាទិទេព Zeus Olympien ឆ្លាក់ដោយ Phidias
La statue en or et en ivoire de Zeus Olympien par Phidias.

៤- វិហារនៃទេវព្រះនាម Artémis នៅ Ephèse.
Le temple d'Artémis à Ephèse.

---

(2) សាស្ត្រាចារ្យនៅសាកលវិទ្យាល័យប៉ារីស I ប្រធានគណៈកម្មការការពារបូជនីយស្ថានជាតិនៅបុសនី អេស៊េហ្គូវីន (Bosnie Herzégovine ) នៅអង្គការយូណេស្កូ ។

៥- មតកចេតិយរបស់ស្តេច ម៉ូសូលនៅហាលីការណាស្ស Le tombeau de Mausole.

៦- បដិមាករធំមហិមានៅរ៉ូដ Le colosse de Rhodes.

៧- សើននៅ អាឡេចសង់ឌ្រី Le phare d'Alexandrie.

<u>**កំណត់ចំណាំ**</u> :អច្ឆរិយវត្ថុទាំង ៧ ខាងលើនេះ លោក Strabon ជនជាតិក្រិចបានសរសេរក្នុងសៀវភៅភូមិវិទ្យារបស់លោក។ លោក Strabon កើតនៅឆ្នាំ 58 មុន គ.ស។

នៅលើពិភពលោកយើងសព្វថ្ងៃ មានអច្ឆរិយវត្ថុជាច្រើនដែលអង្គការយូណេស្កូ ដោយមានការស្នើអំពីប្រទេសសាមីបានបញ្ចូលក្នុងបេតិកភណ្ឌពិភពលោក ដូចជាប្រាសាទអង្គរវត្ត។ តាមខ្ញុំដឹង ប្រទេសកម្ពុជាយើងបានស្នើសុំបញ្ចូលជាបេតិកភណ្ឌពិភពលោក ប្រាសាទបន្ទាយឆ្មា និង ប្រាសាទព្រះវិហារ ភ្នំឪរ៉ាល់ ភ្នំសំកុស និង បឹងទន្លេសាប។ អង្គការយូណេស្កូបានធ្វើបដិរូប ( emblème). នៃបេតិកភណ្ឌពិភពលោកជាផ្លាកសំគាល់ដូចខាងក្រោម។




## *Emblème du patrimoine mondial*

L'emblème du patrimoine mondial symbolise l'interdépendance entre la diversité culturelle et naturelle du monde. Le carré central illustre le produit du savoir-faire et de l'inspiration de l'être humain, et le cercle, les dons de la nature. L'emblème est rond comme le monde et symbolise la protection du patrimoine de l'humanité.

# សេចក្តីប្រែ

បដិរូបនៃបេតិកភណ្ឌពិភពលោក ជានិមិត្តរូបនៃភាពចំណុះគ្នាទៅវិញទៅមក រវាងភាពទីទៃពីគ្នានៃវប្បធម៌ និង ធម្មជាតិរបស់ពិភពលោក។ ការេនៅកណ្តាលធ្វើអោយវិស្សុតផលិតផលកើតចេញជាប៉ិនិន និង បញ្ញាញាណ (ប្រាជ្ញាផុស) របស់មនុស្សលោក និង មណ្ឌលមូលធ្វើអោយវិស្សុត [1] អំណោយធម្មជាតិ។ បដិរូបមានរាងមូលដូច ពិភពលោកហើយជានិមិត្តរូបនៃការការពារបេតិកភណ្ឌនៃមនុស្សជាតិ។

**យ៉ត់ ឌី**

(1) វិស្សុតភាព : illustration ភាពប្រកបដោយកិត្តិនាម។

# ការសិក្សាអំពីឈ្មោះភូមិស្រុក

(តពីទស្សនាវដ្ដីលេខ ១១ ទំព័រ ១៨)

លោក ចែម ផាន អនុប្រធានមន្ទីរ អ.យ.ក ខេត្តកំពង់ចាមបានបន្ថែមឈ្មោះភូមិ-ស្រុកមួយចំនួនដូចខាងក្រោម តាមការអំពាវនាវរបស់គណៈកម្មាធិការនាយក ស.ប.ស.ខ។

**ក្រាំង** : ពាក្យក្រាំងនេះមានឈ្មោះភូមិមួយ ភូមិតាំងក្រាំង ឃុំតាំងក្រាំង ស្រុកបាធាយ ខេត្តកំពង់ចាម។

- **ក្រាំងលាវ** (ភូមិតិរច្ឆាន) កំពង់ឆ្នាំង
- **ក្រាំងយ៉ូវ** (ខេត្តកណ្ដាល)

**ខ្នារ** : ពាក្យខ្នារនេះជាឈ្មោះភូមិមួយ គឺ ភូមិខ្នារ ឃុំស្ដើងជ័យ ស្រុកជើងព្រៃ ខេត្តកំពង់ចាម។

- **ភូមិខ្នារ** ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម។
- **ភូមិខ្នារ** ឃុំខ្នារស ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។

**គោក** : ពាក្យគោកនេះជាឈ្មោះភូមិមួយ គឺ ភូមិគោករវៀង ឃុំគោករវៀង ស្រុកជើងព្រៃ ខេត្តកំពង់ចាម។

- **ភូមិគោកចារ** និង **ភូមិគោកស្រុក** ឃុំគោកស្រុក ស្រុកតំបែរ ខេត្តកំពង់ចាម ។

**ដំបូក** : ភូមិដែលប្រើពាក្យនេះមានភូមិ ដំបូកខ្ពស់ ឃុំស្ដើងជ័យ ស្រុកជើងព្រៃ ខេត្តកំពង់ចាម។

**តាំង** : ក្នុងខេត្តកំពង់ចាមមាន ភូមិតាំងគោក (សម័យសង្គមរាស្ត្រនិយម ឃុំតាំងគោក ស្រុកជើងព្រៃ បច្ចុប្បន្នស្ថិតនៅឃុំសំបួរ ស្រុកបាធាយ។

- **ភូមិតាំងក្រសាំង** ឃុំតាំងក្រសាំង ស្រុកបាធាយ ខេត្តកំពង់ចាម។

**ទួល** : មានឈ្មោះភូមិទួលតាហោ ឃុំគងជ័យ ស្រុកអូរាំងឪ ។

- **ភូមិទួល** ឃុំបាធាយ ស្រុកបាធាយ ។
- **ភូមិទួលសូភី** ឃុំទួលសូភី ស្រុកអូរាំងឪ ខេត្តកំពង់ចាម។
- **ភូមិទួលសំបួរ** ឃុំទួលសំបួរ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។
- **ឃុំទួលព្រះឃ្លាំង** ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។
- **ភូមិទួលស្នួល** ឃុំទួលស្នួល ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម។

**ចែម ផាន**

# ទឹកអង្គ

ខ្ញុំបានសរសេរលិខិត បួន ផ្ញើជូនចំពោះ :

១- លោក ហាក់ សឹងលី ប្រធានមន្ទីរ អ. យ. ក ខេត្តតាកែវ

២- លោក ចាន់ ឃន ប្រធានគណៈកម្មាធិការ ស. ប. ស. ខ ខេត្តកំពង់ស្ពឺ

៣- លោក ភូ តឹកុក ប្រធានមន្ទីរអ.យ.ក ខេត្តកំពត

៤- លោក ថោង ស៊ិន តូ អនុប្រធាន អ. យ. ក. ខេត្តកណ្ដាល

ដើម្បីសូមជួយស្រាវជ្រាវក្នុងខេត្តរបស់លោក នូវឈ្មោះ ភូមិ ឃុំ ស្រុកដែលមានអង្គនៅពីមុខ។

មុននឹងបានចំលើយពីលោកទាំងបួនរូបខាងលើ ខ្ញុំសូមលោកគ្រូ-អ្នកគ្រូ រៀនឆ្ងល់ជាមួយខ្ញុំ ថាតើមូលហេតុអ្វីបានជាខេត្តតាកែវ កណ្ដាល កំពង់ស្ពឺ និង កំពតមានឈ្មោះភូមិស្រុកដែលមានអង្គនៅពីមុខច្រើនម្ល៉េះ ? ។ ដើម្បីបំបាត់ចំងល់នេះ គួរលោកគ្រូ-អ្នកគ្រូសិក្សាស្រាវជ្រាវ ដោយមានការសំនេះសំនាលជាមួយចាស់ព្រឹទ្ធាចារ្យ ឬរាវរកឯកសារសរសេរពីរឿងនេះ។ ខ្លួនខ្ញុំផ្ទាល់មិនទាន់អត្ថនោម័ត ឆ្លើយសំនួរនៅឡើយទេ ដោយមិនមានឯកសារជាបង្អែក។

បន្ទាប់ទៅនេះ យើងគួរអោយន័យ « អង្គ » ជាមុន។ តាមវចនានុក្រមខ្មែរ ទំព័រ 1572 យើងបានដឹងថាអង្គ ជាអង្គជាតិព្រះឥសូរ ឬសិវលិង្គ។ ខ្មែរសម័យបុរាណហៅថ្មដែលធ្វើជារូបសិវលិង្គថា " អង្គ (ហៅកាត់ខ្លីមកពីពាក្យអង្គជាតិ) ហៅថ្មរូប ឧមាយោនី (និមិត្តនាងឧមា) ថាបំពង់ខ្ចី។ ទឹកដែលស្រោចលើថ្មទាំងពីរប្រភេទនេះហៅថា ទឹកអង្គបំពង់ខ្ចី។ ក្នុងសម័យដែលខ្មែរកំពុងកាន់សាសនាព្រាហ្មណ៍ពេញទី ឥស្សរជន និងប្រជាជនច្រើនជីកស្រះសាងអង្គ ទុកជាទីគោរព ក្នុងទីប្រជុំជនមួយៗ សឹងនៅមានរូប និង ឈ្មោះជាប់មកដល់សព្វថ្ងៃនេះច្រើនអន្លើ ដូចយ៉ាងអង្គតាសោម អង្គតារាជ អង្គស្នួល ជាដើម"។

ដោយបានឃើញផ្ទាល់ភ្នែក កាលខ្ញុំជាអធិការបឋមសិក្សានៅខេត្តកំពង់ស្ពឺ នាឆ្នាំ ១៩៦២ ខ្ញុំអាចពិពណ៌នាជូនដូចតទៅ :

ដើម្បីអោយសិរីសួស្ដី ជ័យមង្គលកើតមានដល់ស្រុកភូមិរបស់ខ្លួន ប្រជាជនបានបបួលគ្នាជីកស្រះមួយក្នុងបរិវេណវត្ត គេសង្កេតឃើញច្រើនតែនៅមុខព្រះវិហារ។ នៅពេលកំពុងជីកនោះ គេទុកដីមួយដុំដូចជាកោះនៅកណ្ដាលស្រះ ហើយមានរាងដូចសាជី។ នៅកំពូលកោះតូចនេះ អ្នកស្រុកដំកល់លិង្គព្រះឥសូរ និង ឧមាយោនីទុកជាទីសក្ការបូជា។ ទឹកភ្លៀងដែលធ្លាក់លើសិវលិង្គ និង ឧមាយោនីបង្កើតបានទឹកអង្គបំពង់ខ្ចីហូរធ្លាក់ចូលទៅក្នុងស្រះ។ អ្នកភូមិដងទឹកនេះទៅផឹក និង លុបលាងខ្លួនដើម្បីសុំសេចក្ដីសុខ សេចក្ដីចំរើន រកស៊ីមានបាន។

នៅឆ្នាំ ១៩៦២ នៅពេលដែលខ្ញុំបានទៅកាន់វត្តមួយដែលមានអង្គ ព្រះគ្រូចៅអធិការវត្ត មានពុទ្ធដីកាថា ឥឡូវនេះមិនមានតំកល់សិវលិង្គទៀតឡើយ។ អ្នកស្រុកបានធ្វើរាន (ដូចរានទេវតាសព្វថ្ងៃ) និង បានយកព្រះពុទ្ធរូបមួយអង្គទៅតំកល់នៅក្នុងរានទេវតានោះជំនួសវិញ។

បច្ចុប្បន្ននេះ រានទេវតានោះក្លាយជាព្រះវិហារមួយតំកល់ព្រះពុទ្ធរូប។ នៅកន្លែងខ្លះទៀត គេមិនបានឃើញអង្គ ដូចខ្ញុំបានពណ៌នាមកខាងដើមនោះទេ។ គេមិនបានស្គាល់ អង្គ ថាជាអ្វីឡើយ តែគេស្គាល់តែឈ្មោះភូមិឃុំរបស់គេដែលមានពាក្យ " អង្គ " ។

ដើម្បីរក្សាទុករូបភាព " អង្គ " និង ឧមាយោនីក្នុងរូបារម្មណ៍នៃលោកគ្រូ-អ្នកគ្រូ ខ្ញុំសូមជូនរូបថតនៅទំព័រក្រោយ។

ដើម្បីជូនជ្រាបបន្ថែមអំពីការគោរពបូជាសិវលិង្គ និង ឧមាយោនី ខ្ញុំសូមជំរាបថា នៅខេត្តសៀមរាបជាទំនៀមទំលាប់ ប្រជាជននៅជិតប្រាសាទអង្គរវត្ត និង ប្រាសាទដទៃទៀត នៅពេលចូលឆ្នាំម្តងៗ តែងតែយកទឹកទៅស្រោចលើលិង្គ និង យោនីដែលមាននៅក្នុងប្រាសាទនោះ។ ទឹកដែលហូរធ្លាក់ចុះតាមចង្អូរយោនីត្រូវបានត្រងយកទៅផ្ទះវិញ ដើម្បីរក្សាទុកលុបលាងមុខ រឺប្រោះព្រំលើទ្រព្យសម្បត្តិក្នុងផ្ទះដើម្បីសុំសេចក្តីសុខចំរើន និងសុភមង្គលក្នុងគ្រួសារ។

ឥឡូវនេះ ខេត្តតាកែវ និង ខេត្តកំពង់ស្ពឺ បានផ្តល់ចំលើយមកដល់គណៈកម្មាធិការនាយកមុនគេ។ ដូចនេះសូមលោកគ្រូ-អ្នកគ្រូតាមដានដូចតទៅ :

## ខេត្តតាកែវ

លោកប្រធានមន្ទីរ អ.យ.ក ខេត្តតាកែវបានចាត់លោក ឈូក បុល អគ្គលេខាធិការ ស.ប.ស.ខ ខេត្តអោយធ្វើការស្រាវជ្រាវតាម សំនូមពររបស់ខ្ញុំ។ លោក ឈូក បុល មានប្រសាសន៍ថា « ខ្ញុំបានស្រាវជ្រាវរកឃើញមួយចំនួនធំហើយ តែនៅមិនទាន់អស់ទេ ព្រោះមានកន្លែងខ្លះយើងខ្ញុំមិនស្គាល់ ហើយក៏មិនដែលបានទៅដល់ផង » ។

ខាងក្រោមនេះគឺជាឈ្មោះអង្គដែលមានវត្តអារាម និង សាលារៀនជាទីតាំង។

### បញ្ជីរាយនាមវត្ត និង សាលារៀនដែលមានឈ្មោះ "អង្គ " នៅពីមុខ

### ១- ស្រុកបាទី

| | | | |
|---|---|---|---|
| 1- អង្គសីង្ហ | ឃុំចំបក់ | 2- អង្គរុន | ឃុំត្រពាំងក្រសាំង |
| 3- អង្គ (វត្តអង្គ) | - ត្នោត | 4- អង្គបរិច្ចាគ | - ក្រាំងធ្នង់ |
| 5- អង្គតាភោគ | ឃុំតាំងដូង | 6- អង្គកំនប់ | ឃុំដូង |

### ២- ស្រុកសំរោង

| | | | |
|---|---|---|---|
| 1- អង្គព្រះស្តេច | ឃុំបឹងត្រាញ់ត្បូង | 2- អង្គសូឃ្លាំង | ឃុំជីវរំពេន |

| | | | |
|---|---|---|---|
| 3- អង្គកូវ | - បឹងត្រាញ់ត្បូង | 4- អង្គគោល | - បឹងត្រាញ់ជើង |
| 5- អង្គតាពៅ | ឃុំខ្វាវ | 6- អង្គជុំ | ឃុំខ្វាវ |
| 7- អង្គខ្វាវ | -ដ- | 8- អង្គចង្អេរ | - ស្លា |
| 9- អង្គប្រិយ៍ | ឃុំលំចង់ | 10- អង្គទន្លាប់ | - សំរោង |
| 11- អង្គអង្កុញ | -សំរោង | 12- អង្គរកា | - បឹងត្រាញ់ជើង |
| 13- អង្គក្តី | - សឹង | | |

## ៣- ស្រុកត្រាំកក់

| | | | |
|---|---|---|---|
| 1- អង្គសិទ្ធ | ឃុំស្រែរនោង | 2- អង្គរុន | ឃុំគុស |
| 3- អង្គជុំ | - ពពេល | 4- អង្គត្នោត | - អង្គតាសោម |
| 5- អង្គតាសោម | - អង្គតាសោម | 6- អង្គបក្សី | - ជាងទង |
| 7- អង្គប្រសើរ | - តាភេម | 8- អង្គសមាធិ | - លាយបូរ |
| 9- អង្គរនាប | - ត្រាំកក់ | 10- អង្គមន្ត្រី | - គុស |
| 11- អង្គខ្នារ | - លាយបូរ | 12- អង្គជុំមានលក្ខណ៍ | - តាភេម |
| 13- អង្គស្វែង | - គុស | 14- អង្គធ្នូករង្សី | - អូសារ៉ាយ |
| 15- អង្គសង្កែ | - អូសារ៉ាយ | 16- អង្គស្នាត | - ត្រពាំងធំជើង |
| 17- អង្គឈូក | - ឧត្តមសុរិយា | 18- អង្គសីមា | - សំរោង |
| 19- អង្គរកា | - ត្រពាំងធំត្បូង | 20- អង្គពណ្ណរាយ | - គុស |

## ៤- ស្រុកព្រៃកប្បាស

| | | | |
|---|---|---|---|
| 1- អង្គអំណែត | - តាំងយ៉ាប | 2- អង្គស្វាយចេក | - ចារ |

3- អង្គសង្កែ (សោភណារាម) -ពោធិ៍ចាក

## ៥- ស្រុកកោះអណ្ដែត

1- អង្គសិរីមាលី ឃុំធ្លាប្រជុំ

## ៦- ស្រុកបុរីជលសា

1- អង្គក្រូច ឃុំបុរីជលសា

## ៧- ស្រុកដូនកែវ

1- អង្គមេត្រី ហៅអង្គធ្នូក ឃុំរកាក្នុង

## ៨- ស្រុកត្រាំង

| | | | |
|---|---|---|---|
| 1- អង្គស្តី | ឃុំអង្គខ្នុរ | 2- អង្គកែវ | ឃុំខ្វាវ |

## ៩- ស្រុកគិរីវង់

| | | | |
|---|---|---|---|
| 1- អង្គរុន | ឃុំព្រៃរំដេង | 2-អង្គប្រាសាទ | ឃុំអង្គប្រាសាទ |
| 3- អង្គ | ឃុំកំណប់ | | |

## ១០- ស្រុកអង្គរបុរី

1- អង្គជុំ -ព្រៃផ្គាំ

## ឈ្មោះភូមិឃុំដែលមានប្រជាពលរដ្ឋរស់នៅ និង មិនមានលំនៅនៅក្បែរ

## ១. ក្នុងស្រុកត្រាំកក់

| | | | |
|---|---|---|---|
| 1- អង្គស្លែង | ឃុំលាយបូរ | 2- អង្គសេះ | ឃុំលាយបូរ |
| 3- អង្គតាមោគ | -ដ- | 4- អង្គតាចាន់ | -ដ- |
| 5- អង្គទទា | - ដ- | 6- អង្គកាតី | -ដ- |
| 7- អង្គក្រូច | -ដ- | 8- អង្គតាតុក | -ដ- |
| 9- អង្គប្រាសាទ | -ដ- | 10- អង្គតាកុប | -ដ- |
| 11- អង្គតាទូ | -ដ- | 12- អង្គតាណិប | -ដ- |
| 13- អង្គតាតួយ | -ដ- | 14- អង្គគគី | -ដ- |
| 15- អង្គប្រើស | -ដ- | 16- អង្គដូនលូក | -ដ- |
| 17- អង្គខ្វារ | -ដ- | 18- អង្គដូនអម | -ដ- |
| 19- អង្គឈូកល្បើក | -ដ- | 20- អង្គត្រាំពង ឬ ត្រុំពង | -ដ- |
| 21- អង្គតូច | -ដ- | 22- អង្គតាតឹម | -ដ- |
| 23- អង្គរំពាក់ | ឃុំឧត្តមសុរិយា | 24- អង្គចុងអាង | ឃុំឧត្តមសុរិយា |
| 25- អង្គជាលីតូច | -ដ- | 26- អង្គជាលីធំ | -ដ- |
| 27- អង្គថ្មគោល | -ដ- | 28- អង្គចាក់ជាល | ឃុំពពេល |
| 29- អង្គគគី | ឃុំពពេល | 30- អង្គស្រងាំ | -ដ- |
| 31- អង្គក្រលាញ់ | - ជាងទង | | |

## ២- ស្រុកសំរោង

1- អង្គតាខាន់ ឃុំរំចង់( ឈ្មោះអ្នកកាន់កាប់ពីមុន) 2- អង្គតាឃួនឃុំរំចង់( ឈ្មោះអ្នកកាន់កាប់ពីមុន)

3- អង្គ ( គ្មានឈ្មោះ) នៅខាងកើតភូមិព្រៃឈើទាលវត្តពោធិវ័ន្ត

## ៣- ស្រុកដូនកែវ

| | | | |
|---|---|---|---|
| 1- អង្គខ្នារ | ឃុំរកាក្នុង | 2- អង្គប្រស់ស្វា | ឃុំរកាក្នុង |

### ៤- ស្រុកទ្រាំង

1- អង្គខ្នុរ (ឈ្មោះឃុំមួយ) 2- អង្គត្រាវ ឃុំខ្វាវ

### ៥- ស្រុកគីរីវង់

1- អង្គប្រាសាទ (ឈ្មោះឃុំមួយ)

## ខេត្តកំពង់ស្ពឺ

លោកចាន់ឃន ប្រធានគណៈកម្មាធិការ ស.ប.ស.ខ ខេត្ត បានផ្ញើឈ្មោះសាលារៀនដែលមានពាក្យ "អង្គ" នៅខាងមុខដូចមានក្នុងបញ្ជីខាងក្រោមនេះ។

### ១- ស្រុកគងពិសី

1- អង្គរោង ឃុំមហាឫស្សី (សាលា-វត្ត) 2- អង្គតាព្រះ ឃុំមហាឫស្សី (សាលា-វត្ត)
3- អង្គតាព្រះ -ដ- (អនុវិទ្យាល័យ) 4- អង្គរវៀន - ទឹកល្អក់ ( -ដ- )
5- អង្គភ្នែក ឃុំស្រង់ (សាលា-វត្ត) 6- អង្គអណ្តែត - ជង្រុក ( -ដ- )
7- អង្គជុំ ឃុំរកាកោះ ( -ដ- ) 8- អង្គតាភេម - ស្រង់ ( -ដ- )
9- អង្គក្តី - ព្រៃវិហារ ( -ដ- ) 10- អង្គមន្ទ្រីមី - ព្រៃវិហារ ( -ដ- )
11- អង្គព្រះស្រី - ព្រៃញាតិ ( -ដ- ) 12- អង្គទន្ទាប់ - ព្រៃញាតិ ( -ដ- )
13- អង្គលំទង - ស្នំក្រពើ ( -ដ- ) 14- អង្គព្រះពាន - វាល ( -ដ- )
15- អង្គមានជ័យ -វាល ( -ដ- ) 16- អង្គរមាស -ជង្រុក ( -ដ- )

### ២- ស្រុកច្បារមន

1- អង្គប្រាសាទ ឃុំច្បារមន (សាលា-វត្ត) 2- អង្គសេរី ឃុំសុព័រទេព (ពីមុនមានវត្ត)

### ៣- ស្រុកសំរោងទង

1- អង្គខ្មៅ ឃុំសំបូរ (វត្ត-សាលា) 2- អង្គទន្ទាប់ -សំរោងទង (វត្ត-សាលា)
3- អង្គញាត - តាំងក្រូច ( -ដ- ) 4- អង្គសត្ថា - ធម្មតាអរ ( -ដ- )
5- អង្គពោធិ - ស្គុះ ( -ដ- ) 6- អង្គតាម៉ៅ - តាំងក្រូច ( -ដ- )
7- អង្គស្រង៉ែ - រលាំងគ្រើល ( -ដ- ) 8- អង្គមេត្រី - រលាំងគ្រើល ( -ដ- )
9- អង្គចី - ញាយ ( -ដ- )

### ៤- ស្រុកឧដុង្គ

10- អង្គសណ្តាន់ ឃុំព្រះស្រែ (សាលា-វត្ត) 11- អង្គតាឯក ឃុំភ្នំតូច (សាលា-វត្ត)
12- អង្គតាប៉ុក ឃុំជើងរាស់ (សាលា-វត្ត) 13- អង្គព្រលឹង - ត្រាចទង ( -ដ- )

## ៥- <u>ស្រុកបរសេដ្ឋ</u>

1- អង្គមាស ឃុំផុង ( សាលា-វត្ត)

2- អង្គស្លក ឃុំទូលអំពិល ( -ដ- )

3- អង្គស្លក - ទួលអំពិល ( អនុវិទ្យាល័យ)

4- ត្រពាំងអង្គ - ភារីមានជ័យ ( -ដ- )

5- អង្គទាល - ស្វាយចចិប (វត្ត-សាលា)

6- អង្គតាផល - កក់ ( -ដ- )

7- អង្គលំទង - និទាន ( -ដ- )

8- អង្គខ្នារ - និទាន ( -ដ- )

9- អង្គសាយ - ទួលសាលា ( -ដ- )

10- អង្គអណ្ដែត - ពោធិអង្គ្រង ( -ដ- )

11- អង្គពពេល - ពោធិអង្គ្រង ( - ដ- )

◆◆◆◆◆◆◆

<u>ពន្យល់ពាក្យ</u> : **ត្រាំ**

ឈ្មោះភូមិដែលមានពាក្យត្រាំ ពីមុខដូចជា ត្រាំខ្នារ ត្រាំកក់ ត្រាំសសរ ជាដើមមានន័យថា រយៈផ្លូវល្មមអោយសត្វពាហនៈត្រាំទឹក ផឹកទឹកបាន គឺដំណាក់ពីមួយទៅមួយដែលមានចំងាយផ្លូវដល់មកត្រង់នោះត្រូវតែដាក់រទេះ បញ្ឈប់ដំរី បង្អង់សំរាកសិន ដើម្បីកុំអោយហួសកំលាំងសត្វពាហនៈ ។

(វចនានុក្រមខ្មែរ ទំព័រ 382 )

**សូមនៅស្ងៀមមិនបង្រៀន ប្រសើរជាងបង្រៀនខុស**

សូមកុំសួរថា តើផែនដីបានអោយអ្វីខ្លះដល់អ្នក ?

ប៉ុន្តែគប្បីសួរថា តើអ្នកបានផ្ដល់អ្វីខ្លះហើយដល់ផែនដី ?

ទស្សនៈវិទូក្រិច

ផ្ទាំងទី ១៣០ (ស.វ ទី ៧)



- ព្រះសិវលិង្គ

ចំលងចេញពីសៀវភៅប្រវត្តិសាស្ត្រប្រទេសកម្ពុជា របស់លោកបណ្ឌិត ម. ត្រាណេត ឆ្នាំ 1996



នេះជាឧមាយោទីធ្វើអំពីថ្មខៀវ តំកល់ទុករាប់ពាន់ឆ្នាំមកហើយនៅលើភ្នំស្រែហ្មញ្ញៅ ស្ថិតនៅ ឃុំវាល ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។



**នៅមុខវត្តអង្គព្រះស្រី ហៅវត្តអង្គភាព ស្ថិតនៅឃុំប្រៃញាតិ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ មានស្រះមួយធំ** រាងបួនជ្រុងស្មើ។ ជ្រុងនីមួយៗ ប្រវែងប្រហែល 100ម ។ នៅកណ្តាលស្រះមានទីទួលមួយ។ នៅចំកណ្តាលទួល **គេឃើញរណ្តៅមួយមានកូនឈើដុះពេញ។**

តាជី យាយជីនៅក្នុងវត្តបានផ្តល់ពត៌មានអោយដឹងថា ពីបុរាណកាលនៅកណ្តាលទួលនេះមានខឿនធ្វើពីថ្មរាងបួនជ្រុងស្មើ។ នៅលើខឿនគាត់មិនឃើញ រឺដឹងថាមានតំកល់អ្វីឡើយ។ គាត់មានប្រសាសន៍ថា តាំងពីគាត់ដឹងក្តីមក បានឃើញខឿនតែប៉ុណ្ណឹង។

នាបច្ចុប្បន្នកាលនេះ ខឿនត្រូវបានគាស់រំលើងយកថ្មអស់ហើយ។



នៅមុខវត្តអង្គរមាស ឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ស្រះមួយដ៏មានទឹកថ្លាឆ្វង់ព័ទ្ធជុំវិញព្រះវិហារតូចមួយសង់នៅលើដីទួល ស្ថិតនៅកណ្តាលស្រះ ។ កាលពីមុនព្រះវិហារនេះសាងសង់អំពីឈើ ប្រក់ក្បឿង តែឥឡូវនេះអំពីឥដ្ឋប្រក់ក្បឿង ។

យើងអាចសន្និដ្ឋានបានថា ទីតាំងព្រះវិហារសព្វថ្ងៃជាទីតាំងដំកល់សិវលិង្គ និងឧមាយោនី ។

# ការបំភ្លឺមតិ

លោក ***Jean Piaget*** បានមានប្រសាសន៍ថា ÷

« *គរុកោសល្យ ជាសិល្បៈផង និង ជាវិទ្យាសាស្ត្រផង* »

« ***La pédagogie est un art autant qu'une science*** »

## ការបំភ្លឺ

យើងបានដឹងហើយថាពាក្យបារាំង ***La pédagogie*** ត្រូវបានប្រែមកជាភាសាខ្មែរថា *គរុកោសល្យ* គរុ = គ្រូ ; កោសល្យ = ភាពនៃបុគ្គលអ្នកប៉ិនប្រសប់ ; ការឈ្លាសវៃ ។ យើងទាំងអស់គ្នាយល់ជារៀងរាបមកថា គរុកោសល្យ គឺជាការបង្រៀន ឬវិធីសាស្ត្របង្រៀនរបស់គ្រូ ស្របតាមន័យពាក្យបារាំង La pédagogie ។

លោក ***Piaget*** មានប្រសាសន៍ថា ការបង្រៀនជាសិល្បៈ តើសិល្បៈប្រែថាដូចម្តេច ? សូមជ្រាបថា សិល្បៈក្នុងទីនេះ មិនមែនជាពាក្យដែលប្រើក្នុងវិស័យរបួចមិដូចយើងធ្លាប់ប្រើនោះទេ ។ គេថា ចំលាក់ វិចិត្រកម្ម តន្ត្រី ចំរៀង ជាសិល្បៈ ។ សិល្បៈដែលលោក ***Piaget*** ពោលនេះមានន័យមួយផ្សេងទៀតគឺ ការប៉ិនប្រសប់ ដូចគ្នានឹងពាក្យកោសល្យ ព្រោះការបង្រៀនមេរៀននីមួយៗ សុទ្ធតែមានវិធីសាស្ត្រ ***(méthodologie)*** និង ល្បិច ***(procédés)*** សមស្រប ។ គ្រូប្រើវិធីណាដែលនាំអោយសិស្សងាយយល់ ងាយចាំ ។ នេះជាសិល្បៈក្នុង ការបង្រៀន ។

ការពន្យល់ប៉ុណ្ណេះ គួរចាប់បានហើយ ។ ឥឡូវនេះ យើងនាំគ្នារៀនពាក្យថា គរុកោសល្យជាវិទ្យាសាស្ត្រ ម្តងវិញ ។ វិទ្យាសាស្ត្រក្នុងទីនេះជាប្រព័ន្ធនៃចំណេះដឹងដែលមានកម្មវត្ថុជាក់លាក់ និង វិធីមួយដោយឡែក ។

***Une science est un système de connaissances ayant un objet déterminé et une méthode propre.***

សូមសួរថា គ្រូបង្រៀនគ្រប់រូប មុននឹងចេញទៅធ្វើគ្រូ ត្រូវបានលោកសាស្ត្រាចារ្យគរុកោសល្យ បង្រៀនពី ចិត្តវិជ្ជាកុមារ ចិត្តវិជ្ជាយុវវ័យ រឺ ចិត្តវិជ្ជាទូទៅ ។ ហេតុអ្វីបានជាគេបង្រៀនវិជ្ជានេះ ? គឺដើម្បីអោយបានដឹងពីការ លូតលាស់នៃសរីរាង្គរបស់កុមារា កុមារី និង យុវវ័យ និង ស្គាល់ចិត្ត ឬ ចរិតកុមារថែមទៀត ។ ដូចនេះការ បង្រៀនដោយផ្អែកលើវិទ្យាសាស្ត្រដូចជា សរីរសាស្ត្រ ***( La physiologie)*** និង ពន្ធុវិជ្ជា ***(La génétique)*** ក៏ក្លាយទៅជាវិទ្យាសាស្ត្រ នៃការអប់រំតែម្តង ។

ជារួមគរុកោសល្យមិនមែនគ្រាន់តែជាវិធីសាស្ត្របង្រៀនប៉ុណ្ណោះទេ ។ វាជាវិទ្យាសាស្ត្រអប់រំថែមទៀត ។

**យ៉ង់ ធី**

# ប្រវត្តិកីឡាម៉ារ៉ាតុង

អ្នករត់ម៉ារ៉ាតុង គឺជាអ្នករត់ប្រណាំង ក្នុងចំងាយប្រវែង 42.195 គម ។

ចាប់ពីឆ្នាំ ១៨៩៦ រត់ម៉ារ៉ាតុងជាវិញ្ញាសានៃកីឡាអូឡាំពិក ដែលបានប្រតិស្ឋនាមឡើងដើម្បីជានិមិត្តរូបនៃបេសកកម្មដ៏ធំធេង របស់ទាហានជាតិក្រិករត់ពីតំបន់ម៉ារ៉ាតុង ដល់ក្រុងអាថែន ។

ក្នុងឆ្នាំ ៤៩០ មុន គ.ស ព្រឹត្តិការណ៍នេះបានកើតឡើង ដូចតទៅ :

ព្រះអាទិត្យចាំងចែងនៅលើតំបន់ម៉ារ៉ាតុង គួរអោយត្រេកត្រអាល ។ តំបន់នេះមានចំងាយជាង ៤០គីឡូម៉ែត្រពីក្រុងអាថែនរាជធានីក្រិក ។ ទីនោះប្រជាជនរស់នៅដោយសុខសាន្ត និង សុខសន្តិភាព ។ ... ក៏ប៉ុន្តែឥឡូវនេះ នាថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ ៤៩០ មុន គ.ស កន្លែងនោះក្លាយជាទីពិឃាដ លេចឡើងនូវសំលេងអាវុធ សំលេងគ្រោតគ្រាតរបស់កងទ័ព លុបបំបាត់អស់សំលេងរៃយំ ដូចកាលពីមុនហើយ ។ នៅម៉ារ៉ាតុងមានកងទ័ពពែកស៍ ៣ម៉ឺននាក់ ប្រឈមមុខនឹងកងទ័ពក្រិក ១ម៉ឺននាក់ ។

ឯនាយ គឺសមុទ្រអេហ្សេ ដែលគ្របដណ្ដប់វាលទំនាប និង ឧកវាលខ្សាច់ ជាខណ្ឌសីមារវាងសមុទ្រ និង ភ្នំកំពែងក្រុងអាថែន ។ នៅលើវាលខ្សាច់កងទ័ព៣ម៉ឺននាក់ មានវិន័យ ប្រមូលផ្ដុំនៅទីនោះ ។ គេថាជាកងទ័ពពិសេស ពូកែបាញ់ព្រួញ ពាក់អាវដាយជាសញ្ញានៃជនជាតិតំបន់ឧបទ្វីបខាងកើត ។ នេះ គឺជាកងទ័ពដារីយ៉ុស ស្ដេចរបស់ជនជាតិពែកស៍ ។ ប្រជាជនក្រិកនៅក្រោមអាណាព្យាបាលរបស់អាថែនក្ដៅក្រហាយ ចំពោះវត្តមានកងទ័ពបច្ចាមិត្ត ។ អាថែន មានកំពែងការពារមាំណាស់ តែដារីយ៉ុសបង្ខំបញ្ជូនកងទ័ពទៅបំផ្លាញអាថែន ។

បើដូចនេះ តើអាថែនក្លាយទៅជាយ៉ាងណាដែរ? ។ នៅលើកំពូលភ្នំ ដែលការពារអាថែនមានកងទ័ព ៩ពាន់ នាក់ និង ទ័ពប្លេអ៊ីយ៉ង់១ពាន់នាក់ (ទ័ពសម្ព័ន្ធមិត្ត) មានកន្លែងការពារមាំស្រេចហើយ ។

បន្ទាប់មកកងទ័ពបានប្រឈមមុខគ្នាមួយទល់នឹងបី ... ។

អាថែនដឹងថា សង្គ្រាមនេះមុខជានឹងបរាជ័យហើយ ក៏បញ្ជាអោយបេសកជនម្នាក់រត់ទៅពឹងជនជាតិស្ប៉ាត (រដ្ឋរបស់ក្រិក) អោយមកជួយ ។ រយៈពេល២ថ្ងៃ បេសកជនរត់ពីម៉ារ៉ាតុងទៅស្ប៉ាត និង ត្រលប់មកវិញបាន ក្នុងចំងាយ ២៤០ គីឡូម៉ែត្រ ក៏ប៉ុន្តែជនជាតិនេះមិនអាចជួយធ្វើសង្គ្រាមបានទេ មុនថ្ងៃបុណ្យសាសនារបស់ខ្លួនដែលនឹងប្រព្រឹត្តទៅ ២ -៣ថ្ងៃខាងមុខ ។

កងទ័ពអាថែនអង់អាចណាស់ ល្អីកណារកកងទ័ពជំនួយមិនបានក៏ដោយ ក៏កងទ័ពនេះការពារថ្លៃថ្នូរបំផុត សិទ្ធិសេរីភាពជាតិ និង បូរណភាពទឹកដី ។ ពួកគេស្លៀកពាក់ខ្លី១ ហើយស្ទើង ការពារខ្លួនក្នុងកំពែងមាំ កាន់ខែលដ៏ក្លាហាន ជាកងទ័ពគប់ និងចោលលំពែង ។

លំដាប់ពេលនោះ សង្គ្រាមចាប់ផ្ដើម ។ ទ័ពអាថែនរៀបជាប្រាំបីជាន់ បាញ់ព្រួញចេញពីភ្នំលាន់ដូចព្យុះ ហើយពួកគេគេចផុតពីព្រួញបច្ចាមិត្តចេញពីវាលរាប ។ ឥឡូវគេប្រយុទ្ធគ្នាម្នាក់ទល់ម្នាក់ ទ័ពដារីយ៉ុសរុញច្រានទ័ពក្រិកអោយថយក្រោយ ។ ការដកថយយកល្បិច ទ័ពក្រិករកបង្វែកឡើងវិញ បាញ់ព្រួញដូចទឹកភ្លៀង ស្រពស្រោច

ទៅលើទ័ពពែកស៍អោយងាប់គរជើងលើគ្នានៅជើងភ្នំ ព្រោះគ្មានអ្វីការពារ ។ ពួកពែកស៍រត់ប្រាស់អាយុ ខ្លះលង់ទឹក ខ្លះរត់សំដៅសំពៅដ៏ត្រដាបត្រដួស រត់ចេញទៅប្រទេសពែកស៍វិញ ។ កងទ័ពពែកស៍ស្លាប់រាប់ពាន់នាក់ អាថែមបានជ័យជំនះទាំងស្រុង ... ។

នៅក្នុងសង្គ្រាម កងទ័ពពែកស៍ស្លាប់អស់ ៦៤០០នាក់ ឯក្រិកអស់តែ១៩២នាក់ប៉ុណ្ណោះ ។ នេះជាជ័យជំនះដ៏អស្ចារ្យ ក៏ប៉ុន្តែប្រជាជនអាថែនពុំទាន់បានដឹងទេ ។ ... គេនិយាយថាមានទាហានឈ្មោះ ហ្វីលិព្ពិដេសរត់លឿនណាស់ ទទួលភារកិច្ចទៅប្រាប់ដល់ក្រុងអាថែនពីជ័យជំនះដ៏ថ្លៃថ្លានេះ ។ ក្នុងរយៈពេល ៤ម៉ោង ហ្វីលិព្ពិដេសរត់លឿនជាងទំលាប់របស់គាត់ កំលាំងទាំងឡាយរបស់គាត់ប្រមូលផ្តុំមកលើមូលហេតុដ៏ល្អនេះ គឺបេសកកម្មដ៏ល្អពិសេស ។

ហ្វីលិព្ពិដេសរត់ ... រត់ រត់គ្មានគិតអ្វីទាំងអស់ ។ គេដកដង្ហើមតាមមាត់ មុខឡើងក្រហមច្រាលខ្លួនប្រលាក់សុទ្ធតែ ញើស គេក្តាប់ដៃខំរត់ទៀត រត់ទាល់តែស្ងួតបំពង់កអស់ជាតិទឹកពីខ្លួន ។

ទីបញ្ចប់ មកដល់ក្រុងអាថែនហើយ ប្រជាជនរត់មករកហ្វីលិព្ពិដេស ដែលបាននិយាយថាៈ " យើងសប្បាយទៅ ប្រជាជនក្រិក ! យើងឈ្នះហើយ ! " រួចដួលគ្រេងតែម្តង ... ។

គេនិយាយថា ហ្វីលិព្ពិដេស ស្លាប់ដោយហត់ខ្លាំងពេក ទង្វើដែលគាត់បានអនុវត្ត ក្លាយជាវិញ្ញាសារត់ចំងាយម៉ារ៉ាតុងទី១ក្នុងប្រវត្តិសាស្ត្រ ។

( ប្រែសំរួលពីអត្ថបទលោក **DOMINIQUE GODINEAU, OKAPI 1994** ដោយលោក **ឱ សាន៉ាន់** ប្រធានការិយាល័យរដ្ឋបាលនៃមន្ទីរអប់រំយុវជន និង កីឡាខេត្តកំពង់ចាម ) ។




# លក្ខណៈពិសេសរបស់វ័យជំទង់ (ត.ចប់)

## ៨- ចំណង់ចំណូលចិត្តចំពោះវិជ្ជាជីវៈ

វ័យជំទង់ ជាវ័យដែលពាក់ព័ន្ធទៅនឹងទិដ្ឋភាពសង្គមដូចជា : ជំរើសវិជ្ជាជីវៈ ជំនឿលើខ្លួនឯង ជំនឿលើអ្នកដទៃ និង ការប្រព្រឹត្តល្មើស។ វ័យជំទង់ជាវ័យមានវិបត្តិ និង ទទួលរងការទិតៀន ស្តីបន្ទោសពីមនុស្សចាស់។ ជំទង់ច្រើនមានការត្រិះរិះ និង ជំរើសវិជ្ជាជីវៈមិនទាន់ប្រាកដប្រជាក្នុងចិត្ត។ ជំទង់ច្រើនប្រកាន់យកអាកប្បកិរិយារាយមាយ។ ជំរើសវិជ្ជាជីវៈក្នុងសង្គមរបស់ជំទង់ ច្រើនឋិតនៅក្នុងការស្រមៃ។ ការស្រមៃ និង ឧត្តមគតិរបស់ជំទង់សំបូរបែបណាស់ តែមិនឋិតនៅទៀងទាត់ ឬ ឋិតថេរបានយូរនៅក្នុងចិត្តគំនិតគេឡើយ។

**ឧទាហរណ៍ :** ថ្ងៃនេះគេស្រមៃថា ខ្លួនគេនឹងក្លាយទៅជាអ្នកបើកយន្តហោះ វាយសំរុកទំលាក់គ្រាប់បែកទៅលើពួកសត្រូវឈ្លានពានមាតុភូមិ។ ថ្ងៃស្អែកគេចង់ក្លាយខ្លួនទៅជាអ្នកប្រកួតកីឡាបាល់ទាត់ដណ្តើមបានពានរង្វាន់ផ្តាច់ព្រ័តពិភពលោក។ ថ្ងៃបន្ទាប់មក គេចង់ធ្វើខ្លួនគេអោយទៅជាសិល្បករចំរៀងដ៏ល្បីឈ្មោះ។

បំណងប្រាថ្នា និង ចំណង់ចំណូលចិត្តរបស់ជំទង់ផ្សារភ្ជាប់ទៅនឹង ការតស៊ូ សេចក្តីព្យាយាម និង ការខិតខំប្រឹងប្រែង និង ទាមទារអោយមានជំនួយជ្រោមជ្រែងពីមនុស្សចាស់ផង មានឪពុកម្តាយ និង មជ្ឈដ្ឋានសាលារៀនជាដើម។ ជំទង់ដែលមានភាពខ្ជិលច្រអូស មិនអាចធ្វើអោយការស្រមៃក្លាយទៅជាការពិតតាមបំនងប្រាថ្នារបស់ខ្លួនឡើយ។ គេងាយនឹងបោះបង់ចោលបំណងរបស់គេចំពោះវិជ្ជាជីវៈក្នុងសង្គមណាស់។ ចំពោះជំទង់ដែលមានការតស៊ូព្យាយាម និង អត់ធ្មត់គួបផ្សំ និង ជំនួយជ្រោមជ្រែងផ្គុងផ្តើមពីអ្នកអាណាព្យាបាល ឬ អ្នកអប់រំផងនោះ បំណងប្រាថ្នារបស់គេចំពោះវិជ្ជាជីវៈណាមួយនោះ អាចនឹងបានសំរេចដូចដែលគេ គិតទុក។

**ឧទាហរណ៍ :** ជំទង់ម្នាក់ចង់ក្លាយខ្លួនទៅជាអ្នកចំរៀង ឬជាតន្ត្រីករដ៏ប៉ិនប្រសប់។ អាស្រ័យដោយមានជំនួយជ្រោមជ្រែងពីអ្នកអាណាព្យាបាល ដោយជំទង់នេះព្យាយាម និង មានលំងប់ខ្លាំងទៅលើមុខរបរនេះ ទៅថ្ងៃអនាគតដ៏ខ្លី គេពិតជាអ្នកចំរៀង ឬជាតន្ត្រីករជាប់ចំណាត់ថ្នាក់មែន។

ជំទង់ខ្លះចាប់ផ្តើមប្រព្រឹត្ត និង ប្រកាន់យកអាកប្បកិរិយាតាមមនុស្សចាស់ៗ ឬ បុគ្គលដែលគេរស់នៅស្និទ្ធស្នាលជាមួយ សំរាប់អនាគតរបស់គេ ជាពិសេសគឺគ្រូបង្រៀនដ៏មានប្រជាប្រិយណាម្នាក់នោះ ដែលគេចូលចិត្តជាងគេ។ ការគិត ការក្តាប់បានបញ្ញត្តិ និង ការអភិវឌ្ឍន៍សតិបញ្ញារបស់គេ មិនទាន់ទុំជោរទេ។ ពេលខ្លះជំទង់មិនអាចយល់ច្បាស់ និង កសាងបាននូវបញ្ញត្តិអរូបីឡើយ។ គេត្រូវការអោយមានឧទាហរណ៍ ឬជំនួយពីមនុស្សចាស់ ឬអ្នកមានបទពិសោធន៍។ ពេលខ្លះទៀតជំទង់ហ៊ានធ្វើត្រាប់តាមកាយវិការ និង សំដីនិយាយរបស់មនុស្សចាស់ ជាពិសេសគ្រូរបស់ខ្លួន ក្នុងន័យកំប្លែងសើចលេងសប្បាយ ដោយខ្វះការពិចារណាអោយបានត្រឹមត្រូវ ឬជួនកាលទៀត គេហ៊ានដល់ទៅដាក់ងារ ហៅឈ្មោះក្រៅមួយទៀតអោយមិត្តភក្តិរបស់គេ សំរាប់ការបន្ទុះបង្អាប់សើចលេងកែអផ្សុក កាលណាគេស្ថិតនៅក្នុងចំណោម។

**<u>ឧទាហរណ៍</u>** : ពេលមួយជំទង់ត្រូវធ្វើពលកម្មសង្គមក្រៅសាលារៀន ជំទង់ម្នាក់ធ្វើត្រាប់ដូចបេះបិទ តាមសំដីនិយាយ និង កាយវិការរបស់គ្រូគេម្នាក់ ដែលចូលចិត្តនិយាយកំប្លែងក្នុងម៉ោងបង្រៀន ធ្វើអោយមិត្តភក្តិរបស់គេផ្ទុះសំណើច ...។

## ៩- <u>ទណ្ឌកម្ម និង ការគាបសង្កត់</u>

ការដាក់ទណ្ឌកម្ម ការគាបសង្កត់ ឬ ការអប់រំដោយប្រើហិង្សា ទៅលើជំទង់ក៏ទទួលផលវិបាក ឬលទ្ធផលជាអវិជ្ជមានដែរ។ ការដាក់ទណ្ឌកម្ម ឬ ការធ្វេសប្រហែសចំពោះកូន ត្រូវបានពពួកចិត្តវិទូ អោយនិយមន័យថា ជាការធ្វើអោយកូនមានរបួសខាងផ្លូវកាយ និង ផ្លូវសតិអារម្មណ៍។ មជ្ឈមណ្ឌលជាតិតាមឃ្លាំមើលកុមារ និង ជំទង់ដែលមានទីតាំងនៅក្នុង សហរដ្ឋអាមេរិក បានអោយដឹងថាកុមារ និង ជំទង់ស្លាប់អស់ជាង ២០០០ នាក់ជារៀងរាល់ឆ្នាំ ដោយសារតែការធ្វើបាបដោយការដាក់ទណ្ឌកម្មទៅលើរាងកាយ និង សតិអារម្មណ៍នេះ។ អ្នកដាក់ទណ្ឌកម្មទៅលើកូន ឬ ធ្វើបាបកូន បានន័យថា ខ្លួនឯងធ្លាប់ត្រូវបានគេដាក់ទណ្ឌកម្មដូចកូនខ្លួនឯងដែរ។ ជួនកាលការបង្កអោយមានវិបត្តិរហូតដល់ទៅដាក់ទណ្ឌកម្មកូននោះ បណ្តាលមកពីកូនដែលធ្វើអោយឪពុកម្តាយ ពិបាកគ្រប់គ្រងចចេសរឹងរូស និយាយស្តីប្រដៅមិនស្តាប់សោះ។ ឪពុកម្តាយ ឬអ្នកអាណាព្យាបាលដែលប្រកាន់យកឥទ្ធិពលនៃការដាក់ទណ្ឌកម្មទៅលើកូន ជួនកាលជាអ្នកដែលចូលចិត្តបង្កើតអោយមានហេតុការណ៍តានតឹងក្នុងគ្រួសារ និងចូលចិត្តបង្កអោយមានរឿងអាក្រក់ដើម្បីចាប់កំហុសកូន។ កូនដែលកើតមកមានទំងន់ស្រាល កូនខ្វះការអប់រំល្អក្នុងគ្រួសារ កូនដែលបែកឆ្វេងក្នុងការលូតលាស់សរីរាង្គកាយ កូនកើតមកពិការសរីរាង្គណាមួយ ងាយនឹងឈឺចាប់ និង អាក់អន់ចិត្តណាស់ កាលណាវាទទួលរងទណ្ឌកម្ម ·ឬការគាបសង្កត់។ ការដាក់ទណ្ឌកម្មនេះជួនកាលបណ្តាលមកពីកត្តាផ្សេងៗដូចជា ÷ រស់នៅឃ្លាតឆ្ងាយពីគេឯង រស់នៅមិនបានទទួលពត៌មានអំពីការអប់រំកូន សេដ្ឋកិច្ចគ្រួសារទន់ខ្សោយ មិនឆ្លើយតបបាននឹងតំរូវការកំរិតខ្ពស់ក្នុងគ្រួសារ ...។ ក្មេងជំទង់ខ្លះឆាប់ហត់ហេវ ឬ ងងុយដេកក្នុងថ្នាក់រៀន បណ្តាលមកពីជំងឺប្រចាំកាយ នេះក៏បណ្តាលមកពីការធ្វេសប្រហែសរបស់អ្នកអាណាព្យាបាលដែរ។ អង្គការ ការពារសិទ្ធិកុមារនៅសហរដ្ឋអាមេរិកចាត់ទុកការដាក់ទណ្ឌកម្ម ការគាបសង្កត់ និងការធ្វេសប្រហែសចំពោះកុមារ និង ជំទង់ដោយអនុវត្តច្បាប់តំរូវអោយអ្នកអាណាព្យាបាល ជាប់ទណ្ឌកម្មតាមកំរិតបទល្មើសថ្នាក់មជ្ឈឹម ត្រូវជាប់គុក៦ខែ ឬពិន័យជាប្រាក់ ៥០០ ដុល្លា។

លក្ខណៈធ្វេសប្រហែសរបស់ឪពុកម្តាយចំពោះកុមារ និង ជំទង់អាចត្រូវគេកត់សំគាល់បានដោយងាយ ដូចជា:

- សំលៀកបំពាក់មិនជាទីគាប់ចិត្ត
- សំលៀកបំពាក់រហែកហើយមិនបានបោកគក់
- រាងកាយសុទ្ធតែក្អែល ខ្វះអនាម័យហើយធំក្លិនអាក្រក់
- ខ្វះជីវជាតិអាហារ ដែលមានរស់ជាតិឆ្ងាញ់
- ច្រើនឆាប់ហេវហត់ និង ងងុយដេកក្នុងថ្នាក់រៀន
- ជួនកាលមកដល់សាលារៀនមុនគេ ឬ អវត្តមានញយដង
- ពេលសាលាលុបឈ្មោះចោលលែងអោយរៀន ច្រើនតែមកលេងក្បែរៗ សាលារៀន។

ពពួកចិត្តវិទូ ពិបាកកំនត់វែកញែកអោយច្បាស់លាស់ ចំពោះការដាក់ទណ្ឌកម្ម ការគាបសង្កត់ និង ការធ្វេស ប្រហែសចំពោះកូន របស់អ្នកអាណាព្យាបាល។ ការដាក់ទណ្ឌកម្ម ការគាបសង្កត់ និង ការធ្វេសប្រហែសរបស់អ្នកអាណាព្យាបាល ធ្វើអោយកុមារ និង ជំទង់ទទួលរងផលវិបាកផ្សេងៗ ដូចជា :

- ការព្រួយបារម្ភក្នុងចិត្ត ការខកចិត្ត ការអស់សង្ឃឹម
- មានការភ័យខ្លាច កើតជម្ងឺបាក់ស្បាត
- ទទួលបានពិន្ទុការិតទាប
- ភាពអៀនខ្មាសក្នុងចំណោមមិត្តភក្តិ
- ភាពមិនអាចសំរបសំរួលខ្លួនបានក្នុងដំណោះស្រាយបញ្ហា
- ភាពមិនចុះសំរុងនឹងមិត្តភក្តិ រឺ វិបត្តិផ្លូវចិត្តជាមួយមិត្តភក្តិភេទដូចគ្នា
- មានវិបត្តិផ្លូវចិត្តក្នុងគ្រួសារ និង ការគាបសង្កត់ខ្លាំងពេក
- ដឹងថាខ្លួនមិនអាចមានអនាគតភ្លឺស្វាងដូចគេ ... ។

កត្តាទាំងនេះអាចជំរុញជំទង់ ឬ យុវសិស្សអោយឈានទៅរកការធ្វើអត្តឃាត ឬបោះបង់ចោលគ្រួសារ។ ការធ្វេសប្រហែសខ្លះ បណ្តាលមកពីឪពុកម្តាយ ឬគ្រូមិនមានលក្ខណៈជិតស្និទ្ធនឹងជំទង់ដូចជា :

- មិនទំលាប់អោយកូនជិះរថយន្តជាមួយ ទោះស្ថិតនៅក្នុងភាពបន្ទាន់ក៏ដោយ
- ឪពុកម្តាយមិនធ្លាប់នាំកូនដើរលេង អោយស្គាល់មជ្ឈដ្ឋានច្រើន
- ឪពុកម្តាយដែលមិនធ្លាប់អោបថើបកូន
- កូនរបួសបន្តិចបន្តួចមិនព្រមព្យាបាលនៅផ្ទះ
- គ្រូដែលចោទប្រកាន់សិស្សតាមបែបខុសឆ្គង
- គ្រូដែលនិយមបង្កើតអោយមានភាពតានតឹងជាមួយសិស្ស ...។

ការគាបសង្កត់ ការដាក់ទណ្ឌកម្ម ការធ្វេសប្រហែសសុទ្ធតែជាកត្តា និង មូលហេតុ ធ្វើអោយជំទង់ងាយនឹងបោះបង់ចោលសាលារៀន និងគ្រួសារ ទៅតាមការអូសទាញរបស់បនខិលខូច បក្សពួកបងធំ ផ្តាច់ខ្លួនចេញពីឪពុកម្តាយ ទៅជួលផ្ទះរស់នៅជាក្រុម ដើម្បីប្រព្រឹត្តបទល្មើសផ្សេងៗក្នុងសង្គម។ ជំទង់ខ្លះត្រូវឥទ្ធិពលបនខិលខូចអូសទាញបាន ហើយចចេសមានះនឹងឪពុកម្តាយដើម្បីគ្រាប់តាមកូនអ្នកមានសំបូរបែប។ ជំទង់បែបនេះច្រើនអវត្តមាន

ញឹកញាយដងក្នុងម៉ោងរៀនក្នុងថ្នាក់ ហើយរៀនបានចំណាត់ថ្នាក់ពីមធ្យមមកខ្សោយ ។ ជំទង់ប្រភេទនេះមាន អាកប្បកិរិយាគួរអោយកត់សំគាល់បានដូចជា :

- មិនឆ្លៀតពេលរៀន ឬជួយធ្វើការឪពុកម្តាយនៅផ្ទះ
- ដើរបាត់ពីផ្ទះទៅនៅបនល្បែង ហ្គេម ប៊ីយ៉ា ...
- មករៀនក្នុងថ្នាក់ មិនទៀងទាត់
- ចូលផ្ទះ ឪពុកស្តី ម្តាយជេរ
- ទាមទារសំភារៈប្រើប្រាស់ត្រាប់តាមកូនអ្នកមាន ...

**ក្នុងករណីបែបនេះ អ្នកអាណាព្យាបាលត្រូវជ្រើសរើសវិធានអប់រំជំទង់ តាមរយៈការពន្យល់ណែនាំដូចជា ÷**

- ពន្យល់អោយជំទង់យល់ពីស្ថានភាពគ្រួសារជួបកង្វះខាត
- ទំលាប់កូនអោយដើរផ្លូវល្អ ខំព្យាយាមសិក្សា
- អប់រំណែនាំកូនអោយយល់ពី របៀបស្លៀកពាក់ របៀបហូបចុក អនាម័យ ការប្រើប្រាស់ ថែទាំសំភារៈ ចេះសន្សំសំចៃ ចេះជួយការងារផ្ទះ ចេះឆ្លៀតពេលរៀននៅផ្ទះ ...
- អប់រំកុំអោយសេពគប់សមាសភាពមិត្តមិនល្អ : កូនស្រីនឹងត្រូវគេទិតៀន កូនប្រុសនឹងជាប់ បទប្រព្រឹត្តល្មើស ...
- អប់រំកុំអោយកូនត្រាប់តាមកូនអ្នកមានសំបូរបែប
- បង្កលក្ខណៈងាយស្រួលខាងផ្លូវចិត្ត ខាងផ្នែកសំភារៈសមរម្យដល់កូនក្នុងការសិក្សា
- អប់រំកូន ឬដាស់តឿនកូនអោយចេះគួរសម ចេះប្រកាន់យកសីលធម៌ល្អ
- សហការជាមួយសាលារៀន ដើម្បីតាមដានកូន ...។

## ១០- <u>ការលំបាករបស់សាលារៀនចំពោះជំនទ់</u>

ចំណង់ចំណូលចិត្តរបស់ជំទង់ប្រុស-ស្រី ក្នុងការសិក្សាមុខវិជ្ជាឯកទេសនៅមធ្យមសិក្សាមិនដូចគ្នាទេសិស្ស ខ្លះចូលចិត្តវិទ្យាសាស្ត្រពិត ខ្លះចូលចិត្តវិទ្យាសាស្ត្រសង្គម ។ មជ្ឈដ្ឋានសាលារៀនខ្លះ ខ្វះសំភារៈ និង ឯកសារ សិក្សា លក្ខខណ្ឌសេដ្ឋកិច្ចក្នុងសង្គម ឬ ក្នុងតំបន់មានកំរិតទាប ធ្វើអោយជំទង់មានកំរិតយល់ដឹងខ្សោយ ហើយ ជួនកាលមិនអាចបន្តការសិក្សាទៅមុខបានទៀតឡើយ ។ ជំទង់ខ្លះរៀនបានត្រឹមចប់ថ្នាក់បឋមសិក្សា ។ សាលា មធ្យមសិក្សានៅឆ្ងាយពីផ្ទះ ហើយសេដ្ឋកិច្ចគ្រួសារជួបប្រទះការខ្សត់ខ្សោយ ឪពុកម្តាយគ្មានលទ្ធភាពអោយកូនបន្ត ការសិក្សា ។ តំបន់ឆ្ងាយដាច់ស្រយាលខ្លះ មិនមានសិស្សស្រីជំទង់រៀនចប់វិទ្យាល័យ មកបន្តការសិក្សានៅ ឧត្តមសិក្សា ឡើយ ។ ជំទង់ខ្លះរៀនចប់ថ្នាក់បឋមសិក្សា ឬបោះបង់ចោលថ្នាក់មធ្យមសិក្សា ដើម្បីស្វែងរកការងារ តាមសហគ្រាស ឬតាមរោងចក្រ ឬទៅសាងផ្នួស ឬនៅជួយការងារក្នុងគ្រួសារ ។ ក្មេងស្រីជំទង់មានអាងច្រើនជាង ក្មេងប្រុសជំទង់ ។ គេសង្ឃឹមថាក្រោយពេលរៀនចប់មធ្យមសិក្សា គេនឹងបានរៀបការ ឬឪពុកម្តាយទុកដាក់អោយ មានគូរស្រករឆាប់ៗ ។

ចំពោះពេលសិក្សាក្នុងថ្នាក់រៀន គេសង្កេតឃើញសិស្សជំទង់ប្រុស-ស្រីមានអាកប្បកិរិយាមិនដូចគ្នាទេ ។ ជួនកាលត្រូវជួបការលំបាក និង វាយតំលៃមិនបានត្រឹមត្រូវ ។

<u>ចំពោះក្មេងជំទង់ស្រី</u> :

- មានចរិតស្ងប់ស្ងាត់
- មានស្មារតីប្រុងប្រយ័ត្ន និង យកចិត្តទុកដាក់ក្នុងរយៈពេលយូរជាងសិស្សប្រុស។
- ច្រើនមានស្នាដៃខ្ពស់ និង ទទួលបានពិន្ទុខ្ពស់ផ្នែកវិទ្យាសាស្ត្រសង្គម
- ស្ទិតស្ទាញក្នុងការសិក្សា
- ចេះសហការគ្នាក្នុងការសិក្សា
- ត្រូវការគ្រូគាំទ្រ និង វាយតំលៃខ្ពស់លើសម្បទា ...

<u>ចំពោះក្មេងជំទង់ប្រុស</u> :

- មានចរិតឈ្លានពាន និង មាត់កច្រើន
- ទទួលរងការស្តីបន្ទោសពីគ្រូជាញឹកញាយផង
- មានចរិតសកម្ម ហើយត្រូវបានគ្រូប្រាស្រ័យទាក់ទងច្រើនជាងក្មេងស្រី
- ជួនកាលទទួលចំណាត់ថ្នាក់ទាបលើសម្បទា និង ស្នាដៃ
- ច្រើនបានពិន្ទុខ្ពស់ផ្នែកវិទ្យាសាស្ត្រពិត ... ។

កត្តាសំខាន់ដែលគួបផ្សំគ្នាអាចបង្កលក្ខណៈងាយស្រួល ឬ ផលវិបាកស្មុគស្មាញ ក្នុងការរៀន និងការអប់រំវ័យជំទង់មាន :

- **កត្តាសង្គម** : ឥទ្ធិពលបរិយាកាសសង្គម-សេដ្ឋកិច្ច-ធាតុអាកាស និងតួនាទីរបស់អាជ្ញាធរ
- **កត្តាគ្រួសារ** : ការអប់រំរបស់ឪពុកម្តាយ
- **កត្តាសាលារៀន**: គ្រូ-មិត្តភក្តិ-វិធីបង្រៀន-ខ្លឹមសារមេរៀន-កិច្ចការ-សកម្មភាពផ្សេង១
- **កត្តាជីវសាស្ត្រ** : សុខភាពពីកំណើត របបអាហារប្រចាំថ្ងៃ
- **កត្តាជំណាពូជ** : គ្រួសារល្អ ត្រកូលល្អ ប្រកាន់ទំលាប់ល្អក្នុងការរស់នៅ
- **កត្តាបណ្តាញពត៌មានក្នុងសង្គម** : វិទ្យុ- ទូរទស្សន៍- សារពត៌មាន-ទស្សនាវដ្តី
- **កត្តាឥទ្ធិពលឧបួរចម៉បរទេស** : ខ្សែភាពយន្តវីដេអូអាសអាភាស-បទល្បែង - ពេស្យាចារ កាហ្វេអូខេ - ឃាតកម្ម - ចោរកម្ម - ចាប់ជំរិត - ចាប់រំលោភ-គ្រឿងញៀន ... ។
- **កត្តាសកម្មភាពក្រៅសាលារៀន** : ទង្វើ ឬ សកម្មភាពផ្សេង១ ជាមួយមិត្តភក្តិ ... ។

គឺជំទង់ ដែលបង្កអោយមានការលំបាកដល់មជ្ឈដ្ឋានគ្រួសារតែម្តង ពោលគឺឪពុកម្តាយ និង អ្នកអាណាព្យាបាលជំទង់ដែលមានបញ្ហាច្រើន ដូចជា : ទំនាស់ក្នុងគ្រួសារ ករិតយល់ដឹង និង បទពិសោធន៍ទន់ខ្សោយក្នុងការអប់រំដូចជា :

- កូនដែលឪពុកម្តាយទំរើស និង បណ្តែតបណ្តោយហួសហេតុ
- កូនដែលឆាប់អាក់អន់ចិត្ត
- កូនដែលផ្តាច់ខ្លួនចេញពីចំណោមមិត្តភក្តិដ៏ល្អ
- កូនដែលមានអារម្មណ៍មិនសប្បាយរីករាយ ក្នុងការសិក្សាស្វែងយល់ដោយខ្លួនឯង

- កូនដែលគ្មានទំនុកចិត្តលើខ្លួនឯង ហើយសិក្សាស្វែងយល់ក្នុងថ្នាក់តាមបែបបង្ខំ
- កូនដែលធ្វើអ្វីៗទៅតាមទំនើងចិត្ត មិនចេះពិចារណា ឬ ស្វ័យត្រួតពិនិត្យ
- កូនដែលដើរបាត់ពីផ្ទះមិនចេះឆ្លៀតពេលរៀន ឬ ជួយធ្វើការឪពុកម្តាយ
- កូនដែលទទួលរងការគាបសង្កត់ក្នុងគ្រួសារ
- កូនដែលបាត់បង់ជំនឿជាមួយឪពុកម្តាយ គ្រូ និង សាលារៀន
- កូនកំព្រា និង កូនដែលឪពុកម្តាយលែងលះគ្នា
- កូនដែលឪពុកម្តាយផ្តល់លុយកាក់ ឬ សំភារៈសិក្សាមិនគ្រប់គ្រាន់
- កូនដែលមានអាកប្បកិរិយាច្រឡឹម
- កូនដែលពិការពីកំណើតដោយជំងឺ ឬ ពិការដោយគ្រោះថ្នាក់ណាមួយ
- កូនដែលសេពគប់មិត្តបន មានសមាសភាពមិនល្អ
- កូនដែលមើលមិនឃើញអត្ថប្រយោជន៍នៃការសិក្សា
- កូនដែលគ្មានគំនិតប្រកួតប្រជែង មិនចេះស្វ័យគ្រប់គ្រង មិនចេះស្វ័យវាយតំលៃ មិនចេះភ្ញាក់រលឹកក្នុងការសិក្សា
- កូនដែលឪពុកម្តាយមិនតាមមើលសកម្មភាព
- កូនដែលឪពុកម្តាយនិយាយស្តីមិនស្តាប់ ...។

**<u>សន្និដ្ឋាន</u>**

ដើម្បីអប់រំបុគ្គលិកលក្ខណៈជំទង់អោយចុះសំរុងក្នុងសង្គម មជ្ឈដ្ឋានគ្រួសារ សាលារៀន សង្គម ប្រព័ន្ធផ្សព្វផ្សាយពតិមាន គួរតែឯកភាព និង សហការគ្នា។ ការអប់រំជំទង់ទាមទារអោយមនុស្សចាស់ ឬ អ្នកអប់រំប្រើសញ្ចេតនាអំណត់ធ្មត់ភាពទន់ភ្លន់ និង អហឹង្សា។ បើមជ្ឈដ្ឋានអប់រំទាំងអស់ មិនឯកភាពគ្នាទេ វប្បធម៌ប្រពៃណីជាតិ កាន់តែចុះអន់ថយ ហើយសង្គមទាំងមូលពោរពេញទៅដោយភាពអនាធិបតេយ្យ និង អសន្តិសុខដែលបង្កឡើងដោយបទឧក្រិដ្ឋ ធ្វើអោយសង្គមគ្មានវឌ្ឍនភាពគ្រប់វិស័យទាំងអស់។

**ចាន់ រដ្ឋសុផា**

# បច្ចេកទេសកសាងសំនួរ និង ការប្រតិបត្តិ

## I- សេចក្តីផ្តើម

លោក John Devey បានពន្យល់អោយឃើញថា " ការគិត ជាការសួរ " ។ ការប្រើប្រាស់សំនួរអោយបានសមស្រប អាចបង្កើតនូវបរិយាកាសរៀនមួយប្រកបដោយប្រសិទ្ធភាព។ អ្នកអប់រំតែងមានជំនឿថា បើគ្រូចេះសួរសិស្សបានល្អ នោះមានន័យថា " គ្រូនោះបង្រៀនបានល្អ " ព្រោះថាគ្រូចេះផ្តោតសំនួររបស់គាត់ ទៅលើគោលបំនងមេរៀន។ ដូច្នេះសិស្សក៏អាចទទួលលទ្ធផលសិក្សាល្អទៅតាមនោះដែរ។ ដូច្នេះបំនិនប្រសប់ក្នុងការកសាងសំនួរមានសារៈ សំខាន់ណាស់។ តទៅនេះយើងនឹងរៀបរាប់ថា តើត្រូវកសាងសំនួរដោយរបៀបណា ?

## II- គោលបំនងនៃមេរៀន :

បន្ទាប់ពីបានអានពិភាក្សាប្តូរយោបល់គ្នាលើឯកសារនេះ សិក្ខាកាមអាច :

- ពន្យល់អំពីផលប្រយោជន៍នៃការប្រើប្រាស់សំនួរដែលមានលក្ខណៈសមស្រប
- មានបំនិនក្នុងការបង្កើតសំនួរទាំង ៦កំរិត
-អោយតំលៃទៅលើសំនួរដែលជំរុញការគិតកំរិតខ្ពស់របស់សិស្ស ជាពិសេសប្រភេទសំនួរបែបវិភាគ សំយោគ និងវាយតំលៃ។

## III- និយមន័យ :

សំនួរមានពីរប្រភេទគឺ សំនួបិទ និង សំនួរបើក។ សំនួរបិទសំដៅទៅលើសំនួរដែលអាចមានចំលើយ តែមួយគត់។ សំនួរប្រភេទនេះធ្វើអោយអ្នកកែ មានភាពងាយស្រួល កែដាក់ពិន្ទុបានឆាប់រហ័ស ព្រមទាំងការវាយ តំលៃដាក់ពិន្ទុមានលក្ខណៈសត្យានុម័តទៀតផង។

សំនួរបើកសំដៅលើប្រភេទសំនួរដែលផ្តល់សេរីភាពដល់សិស្សរិះរកមតិនានា ដើម្បីចូលរួមឆ្លើយ ព្រោះសំនួរបើកតែងតែមានចំលើយត្រូវច្រើនលើសពីមួយ។

ខ្លឹមសារមេរៀន : បច្ចេកទេសនៃការកសាងសំនួរ

ក- ប្រវត្តិស្រាវជ្រាវអំពីសំនួរ

តាំងពីសម័យសូក្រាត គាត់បានចាត់ទុកថាការបង្រៀន និង ការចោទជាសំនួរ ជាសកម្មភាពបង្រៀនដែលជាដៃគូជាមួយគ្នា។ គ្រូល្អគឺជាអ្នកសួរល្អ រឺ អ្នកចេះសួរ បានន័យថាគ្រូនោះដឹងថា ពេលណាគេត្រូវសួរ ហើយសំនួរនេះឆ្លើយទៅវត្ថុបំនងមេរៀនមួយណាទៀតផង។

នៅឆ្នាំ ១៩១២ លទ្ធផលរបស់ចិត្តវិទូអប់រំបានរកឃើញថា សកម្មភាពបង្រៀនរបស់គ្រូបានចំណាយយ៉ាងច្រើនទៅលើការចោទសំនួរ និង មតិឆ្លើយតបរបស់សិស្ស។ ប៉ុន្តែបណ្តាសំនួរទាំងនោះភាគច្រើនសង្កត់ធ្ងន់ទៅលើ

ការចាំមាត់ និង ការរំលឹកមេរៀនរបស់សិស្ស។ ហេតុការទាំងនេះបញ្ជាក់អោយដឹងថា លទ្ធផលសិក្សារបស់សិស្ស គ្រាន់តែសើៗ នៅលើមេរៀនតែប៉ុណ្ណោះ។

នៅឆ្នាំ ១៩៧០ ការស្រាវជ្រាវមួយទៀតរបស់ចិត្តវិទូអប់រំបាន បង្ហាញអោយឃើញថា គ្រូភាគច្រើនបាន ប្រើសំនួរជាឧបករណ៍ចំបងក្នុងការបង្រៀន ប៉ុន្តែសំនួរភាគច្រើនរបស់គ្រូសុទ្ធសឹងជាសំនួរ ដែលសិស្សឆ្លើយដោយពុំ បានគិតអោយបានស៊ីជំរៅឡើយ ពោលគឺប្រភេទសំនួរបែបចងចាំ។

លទ្ធផលស្រាវជ្រាវបញ្ជាក់ថែមទៀតថាគ្រូភាគច្រើនពុំទុកឱកាស អោយសិស្សគិតបានគ្រប់គ្រាន់ទេ។ ប្រសិនបើគ្រូទុកឱកាសសំរាប់សិស្សទុកពិចារណានោះ ចំពោះសំនួរកំរិតខ្ពស់នោះបណ្តាលអោយលទ្ធផលសិក្សា របស់សិស្សកើនឡើងជាអតិបរិមាផងដែរ។ លទ្ធផលស្រាវជ្រាវទាំងនោះបញ្ជាក់អោយដឹងថែមទៀតថា គុណភាព និង បរិមាណនៃចំលើយរបស់សិស្សអាចចំរើនទៅបានអាស្រ័យដោយ " គ្រូផ្តល់ពេលវេលាគ្រប់គ្រាន់ សំរាប់អោយ សិស្សគិត " ។ ហេតុនេះ ប្រសិនបើគ្រូបង្កើនរយៈពេលទុកអោយសិស្សគិត អោយបានសមស្របនោះសិស្សនឹងមាន ពេលត្រិះរិះច្រើន ហើយសិស្សនឹងអាចចូលរួមយ៉ាងសកម្មក្នុងម៉ោងបង្រៀនរបស់គ្រូទៀតផង។

ខ- កំរិតទាំង ៦ នៃសំនួរ

ដើម្បីជួយគ្រូអោយសំរេចបំនងមេរៀនបានល្អ នៅឆ្នាំ១៩៥៦ បៃនឡាមិន ប្លូមបានរៀបចំវត្ថុបំនងមេរៀន ជាមួយនឹងបច្ចេកទេសបង្កើតសំនួរទាំង ៦កំរិត ដូចខាងក្រោម :

១- កំរិតទី ១ : កំរិតចងចាំ រឺ ពុទ្ធិ

នេះជាវត្ថុបំនងមេរៀនកំរិតទាបបំផុត ដែលសិស្សមិនចាំបាច់គិតពិចារណាអោយបានស៊ីជំរៅទេ ដោយ គ្រាន់តែនឹកឡើងវិញអ្វីដែលគេធ្លាប់ឃើញ រឺ ចងចាំ។ សំនួរកំរិតនេះច្រើនចាប់ផ្តើមដោយពាក្យ អ្នកណា ? អ្វី ? ចូររៀបរាប់ ...... ? ឯណា .....? ពេលណា..... ?

ឧទាហរណ៍ : អ្នកណានិពន្ធរឿងផ្កាស្រពោន ? .....

សារៈសំខាន់នៃសំនួរចងចាំ :

ការទន្ទេញមេរៀនអោយបានចាំមាត់ក៏មានលក្ខណៈចាំបាច់ដែលសិស្សត្រូវតែមាន ព្រោះនេះជាចំនេះដឹង មូលដ្ឋានដើម្បីឈានទៅរកដល់ការគិតកំរិតខ្ពស់ផងដែរ។

២- កំរិតទី ២ ការយល់

សំនួរប្រភេទនេះ គ្រូតែងតែប្រើដើម្បីធ្វើអោយសិស្សយល់អំពីមេរៀន។ ដើម្បីឆ្លើយទៅនឹងសំនួរនេះ សិស្សមិនគ្រាន់តែចងចាំទេ ប៉ុន្តែត្រូវប្រើការរិះគិតថែមទៀត។

ឧទាហរណ៍ : ចូរពន្យល់ទស្សនៈ " ដំដែក ទាន់នៅក្តៅ " ។

ចូរសង្ខេបដោយប្រើសំដី រឺពាក្យថ្មីរបស់អ្នក ... ?

ចូរបកស្រាយដ្យាក្រាមនេះ ? -ល-

៣- កំរិតទី៣ ការអនុវត្ត

ការដែលសិស្សទន្ទេញអោយចាំ និងបកស្រាយអ្វីដែលគេចងចាំនោះ ពុំទាន់គ្រប់គ្រាន់ទេ ។ សិស្សត្រូវមានសមត្ថភាពយកចំនេះដឹងដែលចងចាំ និង យល់ច្បាស់នោះទៅអនុវត្តទៀតផង ។

ឧទាហរណ៍ : ក) - រថយន្តប្រើសាំងអស់ 20 លីត្រ សំរាប់រត់ 100 គម តើសាំង 70 លីត្រ រថយន្តនោះរត់បានប៉ុន្មាន គម ?

ខ) - ចូររកកំពស់ដើមឈើដោយអនុវត្តទ្រឹស្តី ដែលបានរៀនក្នុង ត្រីកោណសមមាត្រ ?

គ) - ចូររកមាឌរបស់ដុំថ្មមួយ ?

៤- កំរិតទី៤ ការវិភាគ

សំនួរវិភាគជាសំនួរកំរិតខ្ពស់ ដែលតំរូវសិស្សអោយរិះគិតយ៉ាងជិតដល់ និង ស៊ីជំរៅ ។ ដើម្បីឆ្លើយនឹងសំនួរប្រភេទនេះសិស្សត្រូវរិះរកកត្តាផ្សេងៗ ដូចជាសំនួរខាងក្រោម :

តើពន្លឺព្រះអាទិត្យផ្តល់ផលល្អ អ្វីខ្លះដល់មនុស្សជាតិ ? ព្រោះអ្វី ? ហេតុអ្វីបានជាអ្នកត្រូវថែរក្សាបរិស្ថាន? លទ្ធផលស្រាវជ្រាវបានបង្ហាញថាវិភាគមានបីប្រភេទ គឺ ការវិភាគរកមូលហេតុ រឺ បុព្វហេតុដែលបង្កអោយកើតមានឡើង ការវិភាគដើម្បីសន្និដ្ឋានលើដ្យាក្រាម រឺ ពត៌មានដែលទទួលបាន និង ការវិភាគដើម្បីទូទៅកម្មដោយសំអាងលើភស្តុតាង ។

ឧទាហរណ៍ :

ក) កត្តាអ្វីខ្លះ ដែលធ្វើអោយបន្ទាយលង្វែកបាក់បែកក្នុងសម័យឧត្តុង្គ ?

ខ) តើដ្យាក្រាមនៃកំនើនប្រជាជនរបស់ប្រទេសនេះផ្តល់នូវការសន្និដ្ឋានយោបល់យ៉ាងណានៅឆ្នាំ ២០២០?

គ) តើចំនុចណាខ្លះដែលជាភស្តុតាងបញ្ជាក់ថា "ទុំ" មានសេចក្តីក្លាហាន ? ព្រោះអ្វី ?

## ផលប្រយោជន៍ នៃ សំនួរវិភាគ

សំនួរវិភាគនេះមានសារៈសំខាន់ណាស់ វាជាប្រភេទសំនួរបើក ។ ដើម្បីឆ្លើយ រឺ ដោះស្រាយ សំនួរនេះសិស្សចាំបាច់ត្រូវតែគិតពិចារណាទាញនូវគំនិតផ្ទាល់ខ្លួនរបស់គេអោយបានច្រើនយ៉ាងផ្សេងៗ គ្នា ។ ដូច្នេះគ្រូត្រូវតែផ្តល់ឱកាសពេលវេលាអោយបានគ្រប់គ្រាន់ សំរាប់អោយសិស្សគិតពិចារណាភាវរកមតិអោយបានច្រើនបំផុត ដើម្បីជំរុញការគិតកំរិតខ្ពស់របស់សិស្ស ។ នេះជាលក្ខណៈចាំបាច់មួយចំពោះសំនួរវិភាគដែលតំរូវការត្រិះរិះកំរិតខ្ពស់ ។ នៅក្នុងម៉ោងបង្រៀន កាលណាគ្រូប្រើសំនួរនេះមានន័យថាគ្រូជួយសិស្ស រឺ ទំលាប់សិស្សអោយហ្វឹកហាត់ ត្រិះរិះរកអោយឃើញសេចក្តីសំអាងដែលបង្កប់នៅក្នុងរឿងរ៉ាវ ដែលបានកើតមានឡើងរួចហើយ ។

ពាក្យដែលប្រើក្នុងសំនួរនេះមាន :

- រកមូលហេតុ រឺ ហេតុអ្វី ?

- ចូរអ្នកវិភាគរកភស្តុតាង បញ្ជាក់ថាការប្រជុំក្រុមបច្ចេកទេសខ្សែងទាត់ មានឥទ្ធិពលដល់ការសិក្សារបស់សិស្ស។

៥- ក៏រិតទី ៥ : ក៏រិតសំយោគ រឺ សំនួរបែបច្នៃប្រឌិត

សំនួរបែបច្នៃប្រឌិតនេះមានសារៈសំខាន់ណាស់ សំរាប់ទំលាប់សិស្សអោយចេះធ្វើផែនការកម្ម - ការទាយទុកសំរាប់អនាគត និង ការដោះស្រាយបញ្ហា។ នេះវាជាប្រភេទសំនួរបើក។

លទ្ធផលស្រាវជ្រាវបានបញ្ជាក់ថា សំនួរបែបច្នៃប្រឌិត រឺ សំនួរសំយោគនេះចែកចេញជាបីក្រុមដូចជា :

ក) សំនួរតំរូវអោយសិស្សបញ្ចេញស្នាដៃផ្ទាល់ខ្លួន

ឧទាហរណ៍ : ចូរប្តូរអោយចំនងជើងនៃអត្ថបទនេះ ?

អត្ថបទនេះនិយាយអំពីអ្វី ចូរសង្ខេបខ្លឹមសារ ?

ខ) ការទាយទុកសំរាប់អនាគត :

នេះជាប្រភេទសំនួរសំខាន់បំផុត សំរាប់អ្នកធ្វើផែនការ អ្នកធ្វើគំរោងអនាគត អ្នកដឹកនាំគ្រប់គ្រង

ឧទាហរណ៍ : តើជីវភាពប្រជាជននៅជនបទ នឹងទៅជាយ៉ាងណាប្រសិនបើមានផ្លូវគមនាគមន៍ និងអគ្គិសនី ?

គ- សំនួរបែបដោះស្រាយបញ្ហា

នេះជាប្រភេទសំនួរ បែបច្នៃប្រឌិតដើម្បីរកវិធីដោះស្រាយបញ្ហាអ្វីមួយ។

ឧទាហរណ៍ : 1- តើគេផលិតទឹកអប់ដោយរបៀបណា ?

2- តើគេដាំស្វាយដោយរបៀបណា ?

3-តើត្រូវរៀនដោយរបៀបណាដើម្បីអាចមានសមត្ថភាពប្រលងជាប់ចូលមហាវិទ្យាល័យ

4- តើយើងអាចវាស់កំពស់ដើមឈើដោយរបៀបណា ?

សំនួរសំយោគតែងតែចាប់ផ្តើមដោយ :

- ចូរតែងឃ្លា តែងអត្ថបទ .................. តើខ្លឹមសារនេះនិយាយអំពីអ្វី? ចូរដាក់ចំនងជើង ?

- តើមានហេតុការអ្វីកើតឡើង ប្រសិនបើ ..............................

- តើយើងអាចដោះស្រាយបញ្ហានេះដោយរបៀបណា ?

៦- ក៏រិតទី ៦ ការវាយតំលៃ

នេះជាប្រភេទសំនួរក៏រិតខ្ពស់បំផុត។ ដើម្បីឆ្លើយទៅនឹងសំនួរវាយតំលៃ សិស្សត្រូវត្រិះរិះពិចារណា ប្រៀបធៀប រួចហើយធ្វើការសំរេចចិត្តទៅលើមួយណាប្រសើជាង។

ឧទាហរណ៍

ក- នៅប្រទេសកម្ពុជា តើកន្លែងទេសចរមួយណាដែលអ្នកចូលចិត្តទៅទស្សនាជាងគេ ? ព្រោះអ្វី ?

ខ- តើចំរៀងមួយណាដែលអ្នកចូលចិត្តជាងគេ ? ព្រោះអ្វី?

គ- តើសេដ្ឋកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា នឹងទៅជាយ៉ាងណានៅឆ្នាំ ២០១៥ ?

ដើម្បីបង្រៀនសិស្សអោយចេះវិនិច្ឆ័យ ចាំបាច់ត្រូវយកលក្ខណៈវិនិច្ឆ័យជាគោល។ ដូច្នេះគ្រូត្រូវតែពិភាក្សាជាមួយសិស្សអោយចូលរួមបង្កើតលក្ខណៈវិនិច្ឆ័យ មុននឹងឈានទៅរៀនវាយតំលៃអ្វីមួយ។ យ៉ាងណាមិញដើម្បីវាយតំលៃគ្រូ នាយកសាលារៀនត្រូវបង្កើតអោយបានលក្ខណៈវិនិច្ឆ័យ ៤យ៉ាង :

1- មានកិច្ចតែងការបង្រៀនថ្មីទាន់សម័យស្របតាមតំរូវការរបស់សិស្ស

2- គ្រូដឹកនាំការរៀនសូត្ររបស់សិស្សមិនមែនឧទ្ទេសនាមរហូតទេ

3- គ្រូលើកទឹកចិត្តសិស្សអោយចូលរួមគិតពិភាក្សា និង ឆ្លើយ

4- គ្រូវាយតំលៃនៃសកម្មភាពបង្រៀន តើសិស្សទទួលបានកំរិតណា

5- គ្រូខិតខំរៀនសូត្របន្ថែមបណ្តាចំនេះដឹងបច្ចេកទេសថ្មីៗ និង ភាសាបរទេស -ល- ដើម្បីក្លាយខ្លួនជាគ្រូទាន់សម័យជានិច្ច។

## IV- <u>សេចក្តីសន្និដ្ឋាន</u> :

ការយល់ដឹងអំពីបច្ចេកទេសបង្កើតសំនួរទាំង ៦កំរិត ដូចរៀបរាប់ខាងលើ អាចជាពន្លឺសំរាប់គ្រូ នាយកសាលា ក្នុងការជំរុញការគិតច្នៃប្រឌិតរបស់សិស្ស។ ដូច្នេះអ្នកអប់រំទាំងអស់ត្រូវចេះបង្កើតសំនួរទាំង ៦កំរិត ម្យ៉ាងវិញទៀតអ្នកអប់រំទាំងអស់ សូមចងចាំថាសំនួរដែលចាត់ទុកថា មានគុណភាពលុះត្រាតែជា សំនួរខ្លីច្បាស់ ហើយមានគំនិតតែមួយ ព្រោះបើមានគំនិតលើសពីមួយ នាំអោយសិស្សច្រឡំពុំដឹងឆ្លើយយ៉ាងណា។ ហើយគុណភាពនៃចំលើយវាក៏អាស្រ័យទៅនឹងរយៈពេលរង់ចាំរបស់គ្រូ សំរាប់ការគិតទុករបស់សិស្សផងដែរ។

បណ្ឌិត អ៊ិម កុច

# ចំនួនប្រជារាស្ត្រក្នុងស្រុកនៅតាមខេត្ត-ក្រុង (ត)

## ៩-ខេត្តកោះកុង

ស្ថិតនៅតំបន់ឆ្នេរសមុទ្រ មានប្រជារាស្ត្រសរុប 132.106 នាក់ ក្នុងនោះប្រុស 67.700 នាក់ ស្រី 64.406 នាក់ ។ ខេត្តនេះរួមមាន 8 ស្រុក 32 ឃុំ និង 127 ភូមិ ។

ចំនួនប្រជារាស្ត្រតាមស្រុកនីមួយៗ ត្រូវបានបែងចែកក្នុងតារាងខាងក្រោម :

| ល.រ | ស្រុក | ប្រជារាស្ត្រ | | | ដង់ស៊ីតេ |
|---|---|---|---|---|---|
| | | សរុប | ប្រុស | ស្រី | ប្រជាជនរបស់ខេត្ត |
| 1 | បុទុមសាគរ | 18.822 | 9.727 | 9.095 | 12 នាក់ / ១គម² |
| 2 | គិរីសាគរ | 6.289 | 3.259 | 3.030 | ទាបជាងដង់ស៊ីតេកំរិត |
| 3 | កោះកុង | 8.817 | 4.768 | 4.049 | ជាតិ ដែលមាន |
| 4 | ស្មាច់មានជ័យ(ទីប្រជុំជន) | 29.329 | 15.194 | 14.135 | 64 នាក់ /១គម² |
| 5 | មណ្ឌលសីមា | 12.569 | 6.372 | 6.197 | |
| 6 | ស្រែអំបិល | 38.435 | 19.333 | 19.102 | |
| 7 | ថ្មបាំង | 2.880 | 1.411 | 1.469 | |
| 8 | កំពង់សិលា | 14.965 | 7.636 | 7.329 | |

## ១០-ខេត្តក្រចេះ

ស្ថិតនៅក្នុងតំបន់ខ្ពង់រាបនិងព្រៃភ្នំ មានព្រំប្រទល់ភាគខាងកើតឆៀងខាងត្បូង (អាគ្នេយ៍) ជាប់នឹងប្រទេសវៀតណាម ។ មានប្រជារាស្ត្រសរុប 263.175 នាក់ ក្នុងនោះប្រុស 130.254 នាក់ ស្រី 132.921នាក់ ។ ខេត្តនេះរួមមាន 5 ស្រុក 46 ឃុំ និង 257 ភូមិ ។

ចំនួនប្រជារាស្ត្រតាមស្រុកនីមួយៗ ត្រូវបានបែងចែកក្នុងតារាងខាងក្រោម :

| ល.រ | ស្រុក | ប្រជារាស្ត្រ | | | ដង់ស៊ីតេ |
|---|---|---|---|---|---|
| | | សរុប | ប្រុស | ស្រី | ប្រជាជនរបស់ខេត្ត |
| 1 | ឆ្លូង | 50.407 | 24.748 | 25.659 | 24 នាក់ / ១គម² |
| 2 | ក្រចេះ (ទីប្រជុំជន) | 79.123 | 39.235 | 39.888 | ទាបជាងដង់ស៊ីតេ |
| 3 | ព្រែកប្រសប់ | 56.757 | 28.040 | 28.717 | ថ្នាក់ជាតិដែលមាន |
| 4 | សំបូរ | 41.732 | 20.635 | 21.097 | 64 នាក់ /១គម² |
| 5 | ស្នួល | 35.156 | 17.596 | 17.560 | |

## ១១-ខេត្តមណ្ឌលគិរី

ស្ថិតនៅភាគខាងកើត ក្នុងផ្នែកមួយនៃតំបន់ខ្ពង់រាប និង ព្រៃភ្នំ។ មានប្រជារាស្ត្រសរុប 32.407 នាក់ ក្នុងនោះប្រុស 16.380 នាក់ ស្រី 16.027 នាក់ ។ ខេត្តនេះរួមមាន 5 ស្រុក 21 ឃុំ និង 98 ភូមិ ។

ចំនួនប្រជារាស្ត្រតាមស្រុកនីមួយៗ ត្រូវបានបែងចែកក្នុងតារាងខាងក្រោម :

| ល.រ | ស្រុក | ប្រជារាស្ត្រ | | | ដង់ស៊ីតេ |
|---|---|---|---|---|---|
| | | សរុប | ប្រុស | ស្រី | ប្រជាជនរបស់ខេត្ត |
| 1 | កែវសីមា | 8.854 | 4.655 | 4.199 | 2នាក់ / ១គម² |
| 2 | កោះញែក | 8.919 | 4.380 | 4.539 | ដង់ស៊ីតេតិចបំផុតក្នុង |
| 3 | អូរាំង | 2.473 | 1.200 | 1.273 | ចំណោមខេត្តទាំងអស់ |
| 4 | ពេជ្រាដា | 5.129 | 2.556 | 2.573 | |
| 5 | សែនមនោរម្យ (ទីប្រជុំជន) | 7.032 | 3.589 | 3.443 | |

## ១២-រាជធានីភ្នំពេញ

រាជធានីភ្នំពេញគឺជាទីក្រុងដែលរួមមាន 7ខ័ណ្ឌ ។ ក្នុងចំណោមខ័ណ្ឌទាំង 7នេះមាន 4 ដែលជាទីប្រជុំជន នៃរាជធានី ។ រីឯខ័ណ្ឌបីទៀតចាត់ទុកជាជនបទ ។ មានប្រជារាស្ត្រសរុប 999.804 នាក់ ក្នុងនោះប្រុស 481.911 នាក់ ស្រី 517.893 នាក់ ។ ខ័ណ្ឌទាំង 7នៃរាជធានីភ្នំពេញរួមមាន 76 សង្កាត់ និង 637 ភូមិ ។

ចំនួនប្រជារាស្ត្រតាមខ័ណ្ឌនីមួយៗ ត្រូវបានបែងចែកក្នុងតារាងខាងក្រោម :

| ល.រ | ស្រុក | ប្រជារាស្ត្រ | | | ដង់ស៊ីតេ |
|---|---|---|---|---|---|
| | | សរុប | ប្រុស | ស្រី | ប្រជាជនរបស់ខេត្ត |
| 1 | ចំការមន (ទីប្រជុំជន) | 187.082 | 91.850 | 95.232 | 3448 នាក់ /១គម² |
| 2 | ដូនពេញ (ទីប្រជុំជន) | 131.913 | 64.011 | 67.902 | ខ្ពស់ជាងបណ្តា |
| 3 | ៧ មករា (ទីប្រជុំជន) | 96.192 | 46.010 | 50.182 | ខេត្ត-ក្រុងទាំងអស់ |
| 4 | ទួលគោក (ទីប្រជុំជន) | 154.968 | 75.364 | 79.604 | |
| 5 | ដង្កោ | 92.461 | 44.791 | 47.670 | |
| 6 | មានជ័យ | 157.112 | 74.500 | 82.612 | |
| 7 | ឫស្សីកែវ | 180.076 | 85.385 | 94.691 | |

## ១៣-ខេត្តព្រះវិហារ

ស្ថិតនៅលើខ្ពង់រាប និង តំបន់ភ្នំ ដែលមាន ព្រំប្រទល់ភាគខាងជើងជាប់នឹងសាធារណរដ្ឋប្រជាធិបតេយ្យ ប្រជាមានិតឡាវ និង ប្រទេសថៃ ។ ប្រជារាស្ត្រសរុបរបស់ខេត្តមាន 119.261 នាក់ ក្នុងនោះប្រុស 59.333 នាក់ ស្រី 59.928 នាក់ ។ ខេត្តនេះមាន 7 ស្រុក 49 ឃុំ និង 204 ភូមិ ។

ចំនួនប្រជារាស្ត្រតាមស្រុកនីមួយៗ ត្រូវបានបែងចែកក្នុងតារាងខាងក្រោម ៖

| ល.រ | ស្រុក | ប្រជារាស្ត្រ | | | ដង់ស៊ីតេ ប្រជាជនរបស់ខេត្ត |
|---|---|---|---|---|---|
| | | សរុប | ប្រុស | ស្រី | |
| 1 | ជ័យសែន | 15.004 | 7.346 | 7.658 | 9 នាក់ / ១គម² ទាបជាងដង់ស៊ីតេ កំរិតជាតិដែលមាន 64 នាក់ /១គម² |
| 2 |ឆែប | 12.450 | 6.017 | 6.433 | |
| 3 | ជាំក្សាន្ត | 16.073 | 8.478 | 7.595 | |
| 4 | គូលែន | 13.829 | 6.805 | 7.024 | |
| 5 | រវៀង | 26.552 | 13.263 | 13.289 | |
| 6 | សង្គមថ្មី | 13.773 | 6.705 | 7.068 | |
| 7 | ត្បែងមានជ័យ | 21.580 | 10.719 | 98.7 | |

## ១៤-ខេត្តព្រៃវែង

ស្ថិតនៅក្នុងតំបន់ទំនាប ដែលមាន ព្រំប្រទល់ខាងត្បូងជាប់នឹងប្រទេសវៀតណាម ។ ប្រជារាស្ត្រសរុបរបស់ខេត្តមាន **946.042** នាក់ ក្នុងនោះប្រុស **445.140** នាក់ ស្រី **500.902** នាក់ ។ ខេត្តនេះមាន **12** ស្រុក **116** ឃុំ និង **1136** ភូមិ ។

ចំនួនប្រជារាស្ត្រតាមស្រុកនីមួយៗ ត្រូវបានបែងចែកក្នុងតារាងខាងក្រោម ៖

| ល.រ | ស្រុក | ប្រជារាស្ត្រ | | | ដង់ស៊ីតេ ប្រជាជនរបស់ខេត្ត |
|---|---|---|---|---|---|
| | | សរុប | ប្រុស | ស្រី | |
| 1 | បាភ្នំ | 71.662 | 33.479 | 38.183 | 194 នាក់ / ១គម² ខ្ពស់ជាងដង់ស៊ីតេ កំរិតជាតិដែលមាន 64 នាក់ /១គម² |
| 2 | កំចាយមារ | 71.284 | 33.184 | 38.100 | |
| 3 | កំពង់ត្របែក | 106.555 | 50.178 | 56.377 | |
| 4 | កញ្ជ្រៀច | 56.036 | 25.626 | 30.410 | |
| 5 | មេសាង | 92.359 | 42.720 | 49.639 | |
| 6 | ពាមជរ | 66.413 | 32.445 | 33.968 | |
| 7 | ពាមរក៍ | 63.534 | 30.162 | 33.372 | |
| 8 | ពារាំង | 107.958 | 51.361 | 56.597 | |
| 9 | ព្រះស្ដេច | 106.459 | 50.420 | 56.039 | |
| 10 | ព្រៃវែង | 86.932 | 40.480 | 46.452 | |
| 11 | កំពង់លាវ (ទីប្រជុំជន) | 55.054 | 26.271 | 28.783 | |
| 12 | ស៊ីធរកណ្ដាល | 61.796 | 28.814 | 32.982 | |

## ១៥-ខេត្តពោធិសាត់

ស្ថិតនៅក្នុងតំបន់ទន្លេសាប មានទីតាំងនៅទិសបស្ចិមនៃប្រទេស ។ ប្រជារាស្ត្រសរុបរបស់ខេត្តមាន **360.445** នាក់ ក្នុងនោះប្រុស **172.890** នាក់ ស្រី **187.555** នាក់ ។ ខេត្តនេះមាន **6** ស្រុក **49** ឃុំ និង **495** ភូមិ ។

ចំនួនប្រជារាស្ត្រតាមស្រុកនីមួយៗ ត្រូវបានបែងចែកក្នុងតារាងខាងក្រោម :

| ល.រ | ស្រុក | ប្រជារាស្ត្រ | | | ដង់ស៊ីតេ ប្រជាជនរបស់ខេត្ត |
|---|---|---|---|---|---|
| | | សរុប | ប្រុស | ស្រី | |
| 1 | បាកាន | 121.229 | 58.211 | 63.018 | 28នាក់ / ១គម$^{២}$ ទាបជាងដង់ស៊ីតេ កំរិតជាតិដែលមាន 64 នាក់/១គម$^{២}$ |
| 2 | កណ្ដៀង | 53.335 | 25.453 | 27.882 | |
| 3 | ក្រគរ | 74.222 | 35.387 | 38.835 | |
| 4 | ភ្នំក្រវាញ | 54.136 | 26.454 | 27.682 | |
| 5 | សំពៅមាស( ប្រជុំជន) | 57.523 | 27.385 | 30.138 | |
| 6 | វាលវែង | មិនបានជំរឿនប្រជាជនដោយមានអសន្តិសុខ | | | |

# លោកគ្រូ អ្នកគ្រូដឹងទេថា ?

◆បច្ចុប្បន្នមានមនុស្សចំនួន 6 100 លាននាក់រស់នៅលើផែនដីយើងនេះ។

◆ក្នុងមួយឆ្នាំៗ ប្រជាពលរដ្ឋពិភពលោកកើនឡើង 77 លាននាក់។

◆នៅឆ្នាំ 2050 គេប្រមាណថាប្រជាពលរដ្ឋពិភពលោក នឹងឡើងដល់ 9 000 លាននាក់។

◆បណ្ដាប្រទេសមិនសូវរីកចំរើន មានអត្រាកំណើនប្រជាជន 98 ភាគរយពីនេះទៅដល់ឆ្នាំ 2025។

◆ស្ត្រីនៅអាស៊ីសព្វថ្ងៃនេះមានកូនជាមធ្យម 2,6 ទល់នឹង 5,9 កាលពីកន្លងសតវត្សមុន។ អត្រាបង្កកំណើតកូន នៅតាមបណ្ដាប្រទេសអាហ្វ្រិក ជិតវាលខ្សាច់សាហារ៉ា ថយចុះមិនសូវឃើញច្បាស់ទេ។ ពីឆ្នាំ 1950 ទីនោះមានអត្រា 6,5 ហើយឥឡូវនេះនៅត្រឹម 5,5។

◆ ក្ដីសង្ឃឹមនៃការរស់រានមានជីវិតក្នុងលោកសព្វថ្ងៃជាមធ្យម អាយុ 66ឆ្នាំ គឺកើនឡើង 20ឆ្នាំ លើសកាលពីហាសិបឆ្នាំមុន។

( ប្រភព UNFPA )



# " ត " ដាក់ " ,  " ម្តេចអានថា " តុក " ?

ឈ៑ ឈ៑

ទស្សនាវដ្តីលេខ ១២ ទំព័រ ៤៩ លោក ខៀវ ស៊ន នាយកសាលាបឋមសិក្សាខ្ទុរដំបង ស្រុកជើងព្រៃ ខេត្ត កំពង់ចាម បានលើកយកមកបកស្រាយ ដោយមានអំនះអំនាងមកបញ្ជាក់ថា " ត " ដាក់ស្រៈ " , "ម្តេចអានថាតុក? ចំពោះរូបខ្ញុំមានការយល់ដឹងផ្សេងពីលោក ខៀវ ស៊ន ។

ខ្ញុំសូមអនុញ្ញាតពីគណៈកម្មការទទួលខុសត្រូវទស្សនាវដ្តីគ្រូបង្រៀន ខ្ញុំសូមជួយបំភ្លឺដូចតទៅ :

" ត " ដាក់ស្រៈ " , " គួរតែ រី ត្រូវតែអានថា តុ ទើបត្រឹមត្រូវ ជាពិសេសលោកគ្រូ-អ្នកគ្រូយើងងាយស្រួលនឹងបង្រៀនសិស្ស ដោយមិនគប្បីចាត់ទុកថា " តុ អានថា តុក " ជាអញ្ញត្រស័ព្ទឡើយ នាំអោយលំបាកដល់អ្នករៀនអក្សរខ្មែរទាំងជនជាតិយើង និង ជនបរទេស ព្រោះវាខុសពីសច្ចភាព។ រវាងឆ្នាំ ១៩៦៧-៦៨ សម្តេចព្រះមហាសុមេធាធិបតីសង្ឃរាជគណៈមហានិកាយព្រះនាមជួនណាត (ជោតញ្ញាណោ) បណ្ឌិតអក្សរសាស្ត្រខ្មែរដ៏ល្បីល្បាញ និង ជាសកម្មជនវចនានុក្រមខ្មែរតាំងពីឆ្នាំ ១៩១៥ មក ព្រះអង្គបានឆ្លើយនឹង សំនួរខាងលើនេះ ថា [1] "អ្នកណាអោយអានថាតុក ! លោកអានថា តុក ខ្លួនឯង ពីបុរាណមកលោក ក៏អានថា តុ ដែរ ! អាត្មាអាន ថា តុ បុណ្យតាំងតុ តុកៅអី ..." ។

វចនានុក្រមខ្មែរ ទំព័រ ២៤៧ បានបង្ហាញថា :

តុ ន ប្រដាប់ប្រើប្រាស់ ពួកថាសមានជើង : បង្អែមមួយតុ ។

ប្រដាប់មានជើងសំរាប់ទ្រ សំរាប់រងអ្វីៗ : តុសរសេរ ។

គ្រឿងតាំងជាការរុងរឿង ជាលំអក្នុងឱកាសបុណ្យធំនីមួយៗ ក៏ហៅថា តុ ដែរ :

តាំងតុ ព្រះរាជពិធីតាំងតុ - ចំរើនព្រះជន្ម ... ។

**តុករង្វាន់** ន រង្វាន់ដែលរាជការ រឺឯកជនប្រគល់ ជាពិសេសដល់ជនដែលមានគុណវុឌ្ឍិ គួរគេពេញចិត្ត ចង់អោយ ។

<u>ឧទាហរណ៍</u> : គ្រូបង្រៀនល្អ ៤នាក់ សិស្សរៀនពូកែ ២៥នាក់ បានទទួលរង្វាន់ពីគណៈកម្មការប្រលងប្រនាំងរបស់សាលារៀន ។

20 កក្កដា 2001

**អ៊ុយ សុន**

នាយកសាលាបឋមសិក្សាព្រែកកំពឹស ស្រុកកណ្តាលស្ទឹង

---

[1] នៅស្ថានីយវិទ្យុ FM 88 MHZ មានខ្សែអាត់សំលេងសម្តេច ជួន ណាត បកស្រាយពីអក្សរសាស្ត្រខ្មែរ ដែលមានបកស្រាយពាក្យ តុ នេះផងដែរ ។

# ធ្វើដូចម្តេចដើម្បីឈប់ជក់បារី

គណៈកម្មការនាយក បានទទួលអត្ថបទមួយរបស់លោក ឈូក បុល អគ្គលេខាធិការ ស,ប,ស,ខ ខេត្តតាកែវ ស្តីពី វិធីស័ក្តិសិទ្ធិ ដើម្បីបញ្ឈប់ការជក់បារី ដែលយើងខ្ញុំសូមសរុបសង្ខេបជូនដូចតទៅ :

ខ្ញុំ ឈូក បុល កើតឆ្នាំ ១៩៣៦ ។ នៅវ័យកុមារខ្ញុំរៀននៅសាលាបឋមភូមិជាន់ដំបូង វត្តអង្គមេត្រី ឃុំលំចង់ ស្រុកសំរោង ខេត្តតាកែវ ។ ឪពុកខ្ញុំដាំថ្នាំជក់បានច្រើនពោរពាស ។ តែខ្ញុំមិនដែលរវល់ ចង់សាកចង់ល ឡើយ ។ អាយុ ១២ឆ្នាំ ខ្ញុំត្រូវទៅរៀនបន្ត នៅសាលាបឋមភូមិបំពេញវិជ្ជាតាកែវក្រុង ។ ដោយគ្មានផ្ទះបងប្អូន ខ្ញុំត្រូវស្នាក់ នៅក្នុងវត្តសីហារតនារាម ។ រយៈពេល៤ឆ្នាំរស់នៅក្នុងវត្ត ខ្ញុំរៀនជក់ ខ្ញុំចេះជក់បារីជាបណ្តើរៗ ដោយមានព្រះ សង្ឃជាអ្នកផ្តល់អោយ ។ ក្រោយមកការជក់បារីកាន់តែញៀន ជក់កាន់តែច្រើន ព្រះសង្ឃផ្តល់អោយលែងគ្រាន់ ក៏ទិញខ្លួនឯងបន្ថែម ដែលកាលនោះ ១០០ ដើមថ្លៃ៣រៀល (បារីមូរដៃថ្នាំកូតាបកំពង់ចាម) ។ ជូនកាលខ្ញុំជក់ថ្នាំ រាយ មូរស្លឹកសង្កែ អ៊ុតដោយដីខ្សាច់ខ្ចប់ ដាក់លើក្បឿង ដុតភ្លើង រឺដាក់ក្រោមកន្ទេលដេក ។ ម្តងម្កាលខ្ញុំជក់ថ្នាំរាយ ញាត់ក្នុងខ្សៀតែម្តង ។

ដល់ឆ្នាំ ១៩៥៤ ខ្ញុំបានចេញបំរើការងាររាជការជាគ្រូបង្រៀន មានប្រាក់បៀវត្សសមរម្យ ។ ខ្ញុំក៏ជក់បារីកញ្ចប់ថ្នាំខ្លាំង គឺ Bastos កញ្ចប់ខៀវ ។ ក្នុងរបបសាធារណរដ្ឋខ្មែរ ខ្ញុំបានសាកល្បងឈប់ជក់ម្តងដែរ តាមរបៀបពន្យារ និង កាត់បន្ថយការជក់ តែមិនបានសំរេច ។

នៅឆ្នាំ ១៩៩២ ពេលខ្ញុំត្រូវចូលនិវត្ត ខ្ញុំបានពិចារណាលើផលវិបាកនៃការជក់បារី ។ ឧបមាថាខ្ញុំជក់បារីមួយថ្ងៃអស់មួយកញ្ចប់ រយៈពេល ៤៤ឆ្នាំមកនេះ ខ្ញុំជក់អស់ ១៦ ០៦០ កញ្ចប់ស្មើនឹង ៣២១ ២០០ដើម ... តើបានផលអ្វីខ្លះ ? គឺកំលាំងពលំ ចេះតែថមថយ បាត់ស្មារតីចងចាំ ដេកមិនសូវលក់ ញ័រទ្រូង ញ័រដៃញ័រជើង ក្នុងខ្លួនល្ហិតល្ហៃ ក្អកស្ងួតពេលយប់ ស្រកទំងន់ ... នេះមិនគិតពីការខាតបង់ថវិកាផងទេ ។

គួបផ្សំនឹងយុទ្ធនាការផ្សព្វផ្សាយផ្សេងៗ ប្រឆាំងការជក់បារី ផលប៉ះពាល់សុខភាពនៃផ្សែងបារី ទិវាគ្មានថ្នាំជក់,.. ខ្ញុំបានរិះរកវិធីបញ្ឈប់ការញៀនបារី អោយបានសំរេចមួយរយភាគរយ ។ ខ្ញុំនឹកឃើញដល់សំដីលោក តឹម សារិន ដែលជាអតីតនាយកការិយាល័យរបៀបនៃអធិការដ្ឋានបឋមសិក្សាខេត្តតាកែវ គឺការសំរេចចិត្ត ថាឈប់ ហើយក៏ឈប់ជាបន្ទាន់ភ្លាម ដោយធ្វើការតាំងចិត្តម៉ឺងម៉ាត់ យកសញ្ញ័យអោយបានលើការជក់បារី ។

សូមបញ្ជាក់ជូនថា : ការឈប់ជក់បារី ដោយការតាំងចិត្តនេះ ដំបូងមានធ្វើទុក្ខខ្លះៗ ដែរ ដូចជាក្តៅមុខ ក្តៅមាត់ ក្រោយពេលបរិភោគអ្វីហើយ មានភាពរសេះរសោះ ដែលយើងហៅថាជូរមាត់ លំបាកទ្រាំ តែយើងអាចរកអ្វីដែលចត់ៗ មកទំពារ ដូចជាស្លាខ្ចីមួយចំណិតតូច នោះយើងអាចបំបាត់ការជូរមាត់បាន ។ តែកុំទំលាប់ញ៉ីកញាប់ពេក យកល្អ គឺត្រូវតស៊ូទ្រាំអត់អោយបាន ទើបប្រសើរ ។ គ្មានអ្វីធំជាងការសំរេចចិត្តឡើយ ។ ការធ្វើ

ទុក្ខរបៀបនេះមានប្រហែល ២សប្តាហ៍ តែជាការល្អបំផុត គឺយើងត្រូវដុសលាងមាត់ធ្មេញ អោយបានញឹកញាប់ជាង ធម្មតា ដើម្បីអោយឆាប់អស់ជាតិជ័រថ្នាំចេញពីមាត់ ធ្មេញ។

ក្រោយមកយើងនៅមានបញ្ហាមួយចំនួនទៀត ដែលត្រូវជំនះអោយខាងតែបាន ដូចជាជួបមិត្តភ័ក្តិ គេហុចបារី អោយ រឺ បង្ខំអោយជក់ដោយប្រការផ្សេងៗ រឺ នៅកន្លែងធ្វើការ នៅមានអ្នកជក់បង្ហើរក្លិនឈ្ងុយឆ្ងាញ់មកលើយើង រឺក៏រូបភាពផ្សព្វផ្សាយពាណិជ្ជកម្មអំពីបារី រូបភាពអ្នកជក់បារីយ៉ាងសង្ហា មកទាក់ទាញអារម្មណ៍យើង ... -ល- នោះយើងត្រូវពង្រឹងការតាំងចិត្តអោយមាំ កុំអោយភ្លាត់ស្នៀតបានឡើយ។ បើភ្លាត់លើកក្រោយនេះ បានន័យថាជំងឺលាប់ វាអាចធ្ងន់ធ្ងរជាងមុន លំបាកព្យាបាលជាងមុនទៅទៀត។ និយាយរួមគ្មានអ្វីធំជាងការសំរេចចិត្ត និង ការតាំងចិត្តឡើយ។

តើពេលណាដែលយើងសន្និដ្ឋានថាឈប់បាន ?

យើសន្មត់ខ្លួនឯងថាអាចឈប់បានប្រាកដនោះ ទាល់តែពេលធុំក្លិនផ្សែងបារីមិនបាន បណ្តាលទៅជាចង់ពុលទៅវិញ។ ខ្លួនខ្ញុំផ្ទាល់ គឺប្រើរយៈពេលប្រហែលមួយខែទើបបានសំរេច។

ក្រោយពីខ្ញុំឈប់ជក់បារីមកដល់ពេលនេះ ខ្ញុំកត់សំគាល់ឃើញថា : សុខភាពខ្ញុំល្អប្រសើរជាងមុនច្រើន កំលាំង ពលំបង្ហូរ មិនឆាប់ហេវហត់ ហូបបានឆ្ងាញ់ ដេកបានស្រួល លែងក្អក លែងញ៉័រទ្រូង លែងញ័រដៃជើង ភាពចងចាំមាន ច្រើនជាងមុន កើនទំងន់ឡើងដល់ ៥៨ គ.ក (ដែលពីមុនខ្ញុំមិនដែលមានទំងន់លើសពី ៤៥ គ.ក ទេ) គឺត្រូវទិញ ខោ អាវថ្មី ព្រោះឡើងក្បាលពោះ។ តែចំណាយទិញខោអាវជុះ ដែលល្អៗ ហើយមួយឆ្នាំ រឺ ពីរឆ្នាំម្តង ពិតជាធូរ ស្រាលជាងចំណាយសំរាប់ទិញបារីរាល់ថ្ងៃឆ្ងាយណាស់។

សូមមិត្តយើងដែលមិនទាន់ឈប់ជក់បារី មេត្តាធ្វើពិធីតាំងចិត្តជាបន្ទាន់ យកឈ្នះលើបារីដែលជារបស់គ្មានវិញ្ញាណ កុំអោយវាមករួតរិតសុខភាពយើងបានតទៅទៀត។ សូមមិត្តកុំភ្លេច អនុវត្តតាមការណែនាំរបស់លោក តឹម សារិន ដើម្បីសំរេចបានជោគជ័យមួយរយភាគរយ។

សូមអោយបុគ្គលិកសិក្សាទាំងអស់ គ្មាននរណាម្នាក់ជក់បារី ក្នុងពេលដ៏ខ្លីខាងមុខ។

ឈួក ចុល

អគ្គលេខាធិការ ស.ប.ស.ខ

ខេត្តតាកែវ



**បទពាក្យ ៧**

# ត្រី ក្ដិត ក្ដុក ក្ដី

ត្រីក្ដីក្ដុកក្ដិតចិត្តក្លេងក្លាង ចចេសឡើងចាងវាសវាចា
ហែបហែលហ៊ានហក់ហើបហ៊ោហា ហាក់ហាំឆ្លេឆ្លាសង្ហាឫក ។
ជងឹកជងែកជល់ទល់មុខ សង្គ្រាមសង្គ្រប់ពឹតពន្លឹក
សន្ទាប់សន្ទោស្ទូរសន្ទឹក គគ្រេងគគ្រឹកទឹកគគ្រាំ ។
ភាសាគ្រោតគ្រោតលោតក្រញី ខែងរែងសំដីមោះមុតមាំ
ខេខឹងខាំខោកបោកជោរជាំ ទន្ទេងទន្ទាំទាមទារទី ។
ចង់រស់តែឯងមិនបែងចែក ហួងហែងហួរហែកបែកខ្ទេចខ្ទី
មោហ៍បិទចិត្តបាំងស្រវាំងភី វង្វេងវក់វីស៊ីគ្នាឯង ។
ពពួនពាលាភ្លេចពូជពង្ស ឡឹតឡប់លិចលង់ជង់ចំបែង
រាំងរឹះរឹងស្ងួតហោចហួតហែង កណ្ដោចកណ្ដែងកណ្ដាលដី ។
ឈប់ល្ងង់ល្ងីល្ងើភ្លើ ភ្លើនភ្លើត ពព្រើមពព្រើតព្រើលអប្រិយ៍
ទោះពូជខុសគ្នាក្ដុក ក្ដិត ក្ដី តែជាតិជាត្រីដូចតែគ្នា ។
ចូរចេះចាត់ចែងចែកគ្នារស់ ទន្លេបឹងជ្រោះជ្រៅគង្គា
ជ្រកកោនអោនអត់ក្នុងជលធារ ទើបជន្មាជាផុតភ័យ ។

**ជ័យ ចាប**

- អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និង កីឡា
- អគ្គស្នងការសមាគមកាយរឹទ្ធិកម្ពុជា

# ករណីពិសេស

**ក.៦** អង្គការគ្រូសារថ្មីបានស្នើសុំគណៈកម្មាធិការនាយក ស.ប.ស.ខ

បោះពុម្ពផ្សាយអត្ថបទ ពីរ ដូចខាងក្រោម ក្នុងគោលបំណង :

ទី១ : អោយគ្រូយើងស្គាល់ពីអង្គការនេះ ដែលជាអង្គការជួយចិញ្ចឹមបីបាច់ថែរក្សា និង អប់រំកុមារ កំព្រា និង អនាថាជាយូរឆ្នាំមកហើយ ។ បច្ចុប្បន្ននេះអង្គការទទួលបានជោគជ័យលើផ្នែកអប់រំកុមារពិការភ្នែក និង កុមារគ ថ្លង់ ។

ទី ២ : ផ្សាយល្បែងអប់រំមួយដែលមានឈ្មោះថា " **ផ្លូវណាដឹង** " ។ គឺជាល្បែងនាំអោយសិស្សសប្បាយរីករាយក្នុងការរៀនសូត្រ ។

សូមលោកនាយកសាលាទាក់ទងអង្គការគ្រូសារថ្មីស្នើសុំល្បែង **ផ្លូវណាដឹង** ដើម្បីអោយសិស្សបានរៀនសូត្រ តាមរយៈការលេងល្បែងនេះ ។

★★★★★

# អង្គការគ្រូសារថ្មី និង ថ្នាក់សមាហរណកម្ម

អង្គការគ្រូសារថ្មី គឺជាអង្គការខ្មែរមួយដែលមិនមានពាក់ព័ន្ធនិន្នាការនយោបាយ រឺ សាសនាណាមួយឡើយ។ អង្គការនេះត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩១។ គោលបំនងរបស់អង្គការគ្រូសារថ្មី គឺជួយអភិវឌ្ឍកុមារកម្ពុជាដែលស្ថិតនៅក្នុងការលំបាកខ្លាំង អោយក្លាយជាមនុស្សពេញវ័យប្រកបដោយសមត្ថភាព មានគំនិតផ្ដួចផ្ដើម និង មានស្មារតីទទួលខុសត្រូវ។ អង្គការគ្រូសារថ្មី ផ្ដល់ជូនកុមារទីទ័លក្រ នូវសំភារៈស្បៀងអាហារ ការអប់រំ និង ការគាំទ្រផ្នែកសង្គម។ គ្រប់សកម្មភាព និង ជំនួយឧបត្ថម្ភរបស់ខ្លួន ត្រូវធ្វើឡើងអោយសមស្រប និង បរបទកម្ពុជា ពោលគឺគោរពតាមជំនឿ ទំនៀម ទំលាប់ប្រពៃណីវប្បធម៌ប្រទេសកម្ពុជាដើម្បីពលរដ្ឋកម្ពុជា។ គ្រូសារថ្មីគាំទ្រយ៉ាងសកម្មនូវការចូលរួមរបស់ដៃគូក្នុងស្រុក ក្នុងទិសដៅអភិវឌ្ឍយូរអង្វែងនូវរាល់កម្មវិធីទាំងអស់របស់គ្រូសារថ្មីដែលត្រូវបានចាត់ចែង និង ដំនើរការដោយពលរដ្ឋកម្ពុជា ដើម្បីពលរដ្ឋកម្ពុជា។ បច្ចុប្បន្នគ្រូសារថ្មី

ដំណើរការកម្មវិធីរបស់ខ្លួនលើផ្នែកធំៗបីគឺ សុខមាលភាព ការអប់រំ និង ជំនួយផ្នែកអប់រំ និង ការជួយអភិវឌ្ឍ សិល្បៈវប្បធម៌ ។ ជាង ១០ ឆ្នាំកន្លង ទៅនេះ គ្រួសារថ្មីទទួលបានជោគជ័យជាច្រើនលើកម្មវិធីរបស់ខ្លួន ជាពិសេស លើផ្នែកអប់រំ កុមារពិការភ្នែក និង កុមារ គថ្លង់។

ការអប់រំ ជាវិស័យដ៏សំខាន់មួយដែលរាជរដ្ឋាភិបាលបាន និង កំពុងយកចិត្តទុកដាក់ ជំរុញអោយមាន គុណភាពល្អ និង ការរីកចំរើន នៅទូទាំងប្រទេសកម្ពុជា ទោះជានៅទីក្រុង រឺ ក៏ជនបទក៏ដោយ សមស្របទៅនឹង ពាក្យថា " ការអប់រំសំរាប់ទាំងអស់គ្នា " ។ កុមារទាំងអស់មានសិទ្ធទទួលការអប់រំទោះពួកគេជាកុមារពិការ ក៏ដោយ។ កន្លងមកការអប់រំកុមារពិការ មិនត្រូវបានគេយកចិត្តទុកដាក់ឡើយ ទើបតែពេលនេះអង្គការគ្រួសារថ្មី បាននិងកំពុង ចូលរួមលើកស្ទួយនូវសិទ្ធិទទួលការអប់រំរបស់កុមារពិការភ្នែក និងគ ថ្លង់នៅកម្ពុជា។ បច្ចុប្បន្ននេះ ជាពេលវេលាមួយដ៏សក្តិសមហើយ ដែលប្រទេសកម្ពុជាយើងគួរតែផ្តល់នូវសេវាអប់រំកុមារពិការអោយបានទូលំ ទូលាយដល់កូនចៅយើង ដើម្បីពួកគេអាចទទួលបាននូវការអប់រំ និង ចូលរួមចំណែកអភិវឌ្ឍប្រទេសយើងនាពេល អនាគត។

សាលាកុមារពិការភ្នែកទី ១ នៅក្នុងរាជាណាចក្រកម្ពុជា ត្រូវបានបង្កើតឡើងដោយអង្គការគ្រួសារថ្មី ដោយមានកិច្ចសហការជាមួយក្រសួងអប់រំ យុវជន និង កីឡា នៅឆ្នាំ១៩៩៣ ដែលមានទីតាំងស្ថិតនៅ ភូមិដើម ស្លែង សង្កាត់ច្បារអំពៅ ២ ខណ្ឌមានជ័យរាជធានីភ្នំពេញ។ បន្ទាប់មកទៀតនៅខែកញ្ញាឆ្នាំ ១៩៩៦ សាលាកុមារ ពិការភ្នែកទី ២ បានចាប់បើកជាផ្លូវការនៅក្នុងទីរួមខេត្តបាត់ដំបង។ បច្ចុប្បន្នសាលាទាំងពីរនេះមានសិស្សប្រមាណ ជាង ១០០ នាក់ហើយកំពុងរៀនពីថ្នាក់ទី ១ ដល់ថ្នាក់ទី ៧ ទៅតាមកម្មវិធីរបស់ក្រសួងអប់រំ យុវជន និង កីឡា។ បច្ចុប្បន្នពួកគេទទួលបានភាពម្ចាស់ការច្រើនលើខ្លួនឯង មិនសូវពឹងផ្អែកលើអ្នកដទៃដូចពេលមុន។ គ្រូជំនាញបាន និង កំពុងបង្រៀនក្មួយៗពិការភ្នែកអោយចេះដើរដោយខ្លួនឯង ចេះធ្វើចលនាដោយសុវត្ថិភាពនិងចេះរកទិសដៅ។ សិស្សពិការភ្នែកស្ទើរតែទាំងអស់ ត្រូវបាបញ្ជូនទៅរៀននៅសាលាបឋមសិក្សាចំណេះទូទៅ ជាមួយកុមារធម្មតានៅ ពេល ដែលគេចេះអាន និង សរសេរអក្សរប្រៃយ៍ (អក្សរពកៗ សំរាប់អ្នកពិការភ្នែក) សិស្សពិការទាំងអស់ ត្រូវប្រើម្រាម ដៃដើម្បីអានអក្សរប្រៃយ៍ខ្មែរដែលបានរៀបចំបោះពុម្ពដោយអង្គការគ្រួសារថ្មី ។

ទន្ទឹម និងការអភិវឌ្ឍលើវិស័យអប់រំលើកុមារពិការភ្នែកនៅក្នុងរាជាណាចក្រកម្ពុជា អង្គការគ្រួសារថ្មី ក៏បានអភិវឌ្ឍលើការអប់រំសំរាប់កុមារគ ថ្លង់ នៅក្នុងរាជាណាចក្រកម្ពុជាផងដែរ។ សាលាកុមារគ ថ្លង់ទី ១ នៅ ក្នុងរាជាណាចក្រកម្ពុជាត្រូវបានបង្កើតឡើងដោយអង្គការគ្រួសារថ្មី សហការជាមួយក្រសួងអប់រំយុវជន និង កីឡា នៅក្នុងឆ្នាំ ១៩៩៧។ សាលានេះស្ថិតនៅភូមិនិរោធន៍ សង្កាត់និរោធន៍ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។ ឯសាលា កុមារគថ្លង់ទី ២ ត្រូវបានបង្កើតឡើងនៅក្នុងខេត្តសៀមរាប តាមបណ្តោយផ្លូវទៅអង្គរ នៅក្នុងឆ្នាំ ២០០០ ហើយ ត្រូវបានសម្ពោធជាផ្លូវការ នៅថ្ងៃទី ៤ ខែមករា ឆ្នាំ ២០០១ ។ សាលាគ ថ្លង់មួយទៀតក៏ត្រូវបានបង្កើតឡើងដែរ នៅក្នុងបរិវេណសាលាកុមារពិការភ្នែកបាត់ដំបង។ បច្ចុប្បន្នមានសិស្សថ្លង់ប្រមាណ ២០០នាក់កំពុងរៀនពីថ្នាក់ទី១ ដល់ថ្នាក់ទី ៤។ សិស្សានុសិស្សគ ថ្លង់ទាំងអស់កំពុងរៀនភាសាសាមញ្ញដោយទឹកចិត្តរីករាយ និង ក្តីសង្ឃឹមហើយ

ពួកគេទទួលការអប់រំផ្សេងៗ ទៀតនៅក្នុងសាលា ស្របតាមពិការភាពរបស់ពួកគេ។ សិស្សគ ថ្លង់ទាំងអស់ អាចប្រើប្រាស់ភាសាសាមញ្ញមួយ ដើម្បីងាយស្រួលក្នុងការប្រាស្រ័យទាក់ទងគ្នានៅទូទាំងប្រទេស។ នៅបវេសនកាលនេះសិស្សថ្នាក់ទី ៣ និង ទី ៤ ត្រូវបញ្ជូនអោយទៅរៀននៅសាលាចំណេះទូទៅមួយពេល ដើម្បីអោយពួកគេអាចរៀនសូត្របានជាមួយកុមារធម្មតា។

ដោយយល់ឃើញថារាជរដ្ឋាភិបាល និងក្រសួងអប់រំពុំទាន់មានលទ្ធភាពបន្ត និង ពង្រីងការអប់រំកុមារពិការ នៅក្នុងប្រទេសកម្ពុជានៅឡើយ អង្គការគ្រួសារថ្មីបានពុះពាររាល់ការលំបាកដើម្បីពង្រីកកម្មវិធីអប់រំកុមារពិការភ្នែក និង កុមារគ ថ្លង់នេះ នៅទូទាំងប្រទេសកម្ពុជាក្នុងគោលបំណងលើកដំកើងនូវសិទ្ធិទទួលការអប់រំរបស់កុមារពិការភ្នែក និងកុមារគ ថ្លង់។ ចំនួនកុមារពិការភ្នែកនៅមានច្រើនពាសពេញរាជាណាចក្រកម្ពុជា ដែលមិនទាន់បានចូលរៀន ព្រោះថាសាលាទាំងប៉ុន្មាន ដែលបានបង្កើតឡើង ដោយអង្គការគ្រួសារថ្មីមិនទាន់គ្រប់គ្រាន់ឆ្លើយតបទៅនឹងតំរូវការរបស់ពួកគេ ហេតុនេះហើយថ្នាក់សមាហរណកម្មកុមាពិការភ្នែក និង គ ថ្លង់ ត្រូវបានបង្កើតឡើង។ គឺជាថ្នាក់រៀនសំរាប់សិស្សគថ្លង់ និងសិស្សពិការភ្នែកនៅក្នុងសាលាចំណេះទូទៅ។ ពោលគឺ កុមារពិការភ្នែក និង កុមារគ ថ្លង់ អាចចូលរៀនបាននៅតាមសាលាចំណេះទូទៅនានាដូចកុមារធម្មតាដែរ។ ជំហានដំបូងសិស្សពិការទាំងពីរប្រភេទខាងលើនេះត្រូវរៀន ដោយឡែកពីសិស្សធម្មតា រហូតដល់ពួកគេអាចចេះអាន និងសរសេរបានទើបបន្ថែមម៉ោងសំរាប់រៀនចូលគ្នាជាមួយកុមារធម្មតា។ ថ្នាក់សមាហរណកម្មអាចដំណើរការទៅនៅគ្រប់សាលាចំណេះទូទៅដែលមានលទ្ធភាពប្រមូលសិស្សពិការភ្នែក រឺ កុមារគ ថ្លង់ ចាប់ពី ១០នាក់ឡើងទៅ។ កម្មវិធីនេះនឹងចាប់ផ្តើមនៅបវេសនកាលឆ្នាំ ២០០១-២០០២ ខាងមុខនេះ នៅសាលាមួយចំនួនក្នុងបណ្តាខេត្តក្រុងមួយចំនួនដូចជានៅ បាត់ដំបង ពោធិ៍សាត់ សៀមរាប តាកែវ កណ្តាលជាដើម។

ទោះជាយើងជួបនូវការលំបាកជាច្រើន ក្នុងការស្វែងរកថវិការដើម្បីទ្រទ្រង់កម្មវិធីទាំងអស់នៅក្នុងអង្គការគ្រួសារថ្មី ក៏យើងនៅតែជំនះ ពង្រីកនូវសេវាអប់រំ កុមារពិការនៅកម្ពុជាអោយបានកាន់តែទូលំទូលាយឡើង។ កម្មវិធីទាំងអស់នេះនឹងមិនអាចដំនើរការទៅមុខ ប្រកបដោយជោគជ័យទេ ប្រសិនបើគ្មានការគាំទ្រ និងយកចិត្តទុក ដាក់ពីសម្តេចព្រះករុណាព្រះបាទនរោត្តម សីហនុ និង ព្រះរាជអគ្គមហេសី ជាទីសក្ការៈ និង ជំនួយដ៏ឧត្តុង្គឧត្តមពី សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលប្រទេសកម្ពុជា។ ឆ្លៀតក្នុងឱកាសនេះផងដែរ យើងខ្ញុំសូមថ្លែង អំណរគុណដល់គ្រួសារថ្មី ប្រទេសស្វីស TDH ហូឡង់ និង Fondation Suez ប្រទេសបារាំងដែលបានជួយឧបត្ថម្ភ ដល់អង្គការគ្រួសារថ្មីក្នុងការដំណើរការកម្មវិធីអប់រំកុមារនៅកម្ពុជា។

# ល្បែងអ្នកណាដឹង ?

គ្រួសារថ្មីគឺជាអង្គការខ្មែរ ក្រៅរដ្ឋាភិបាលមួយដែលជួយកុមារកម្ពុជាស្ថិតក្នុងការលំបាក ដើម្បីអោយពួកគេ ក្លាយទៅជាមនុស្សពេញវ័យ ប្រកបដោយសមត្ថភាព និង ការទទួលខុសត្រូវ។ ដើម្បីសំរេចបាននូវគោលបំនងនេះ កុមារទាំងអស់ត្រូវមានចំនេះដឹងទូទៅជាមូលដ្ឋាន រួមផ្សំ និង ចំនេះដឹងទាំងឡាយដែលបានក្រេបជញ្ជក់ រៀនសូត្រ នៅក្នុងសាលាចំនេះទូទៅនៃក្រសួងអប់រំ យុវជន និង កីឡា។ កន្លងមកយើងធ្លាប់សាកសួរសំនួរខ្លះៗដល់កុមាររបស់យើង ដែលទើបប្រលងជាប់សញ្ញាប័ត្រទុតិយភូមិថ្មីៗ ដែលមានដូចជាសំនួរទាក់ទង នឹងប្រាសាទអង្គរវត្ត សង្គ្រាមលោកជាដើម ដែលកុមាររបស់យើងមិនអាចឆ្លើយបានត្រូវៗ ទៅនឹងសំនួរងាយៗទាំងនោះ។ ហេតុផលនេះធ្វើអោយយើងមានការខ្វល់ខ្វាយក្នុងការលើកកំពស់ការចងចាំរបស់ពួកគេ ហើយក៏ធ្វើអោយលោក ប៊ីណ័រ ឱយសាតូ អាម៉ាំងហ្សេងប្រធានស្ថាបនិកអង្គការគ្រួសារថ្មី មានគំនិតថាគ្រួសារថ្មីត្រូវតែរៀបចំជាល្បែងអប់រំមួយ ដើម្បីអោយពួកគេអាចរៀនបានតាមរយៈការលេងនេះ។ ល្បែងដែលត្រូវបានរៀបចំបង្កើតឡើងដោយអង្គការគ្រួសារថ្មី នោះមានឈ្មោះថា " **អ្នកណាដឹង** "។ ការលេងល្បែងដែលបង្កប់ដោយការអប់រំ អាចធ្វើអោយកុមារ និង យុវជនយើងចងចាំបាននូវចំនេះដឹងផ្សេងៗដែលបង្កប់នៅក្នុងល្បែងនោះគឺ " អ្នកណាដឹង " អាចបណ្ដុះប្រាជ្ញាស្មារតីកុមារ និង យុវជនកម្ពុជាអោយមាន ការជ្រួតជ្រាប និង ចងចាំកាន់តែច្រើនឡើងនូវចំនេះដឹងទូទៅជុំវិញប្រទេសកម្ពុជា និង ពិភពលោក។ ដើម្បីលេងល្បែងនេះ អ្នកលេងត្រូវឆ្លើយទៅនឹងសំនួរផ្សេងៗដែលទាក់ទងអំពីសុជីវធម៌ ប្រវត្តិវិទ្យា ភូមិវិទ្យា អក្សរសាស្ត្រ វិទ្យាសាស្ត្រ-ល- និង-ល- ។

" អ្នកណាដឹង " ជាល្បែងអប់រំសំរាប់កុមារ ពីអាយុ ១០ ឆ្នាំឡើងទៅ ដែលអាចលេងចាប់ពី ២ ទៅ ៥នាក់ រឺ ចាប់ពី ២ក្រុមឡើងទៅ។ កុមារមានការសប្បាយរីករាយរៀនសូត្រតាមរយៈការលេងល្បែងនេះ ដែលអាចនិយាយបានថា "លេងគឺរៀន"។ នៅក្នុងល្បែងនេះ ជារូបមានបន្ទះក្ដារសំរាប់ដើរកូនប្រដាប់ដោយពណ៌ចំរុះ ដែលដំណាងអោយមុខវិជ្ជាផ្សេងៗ ឧទាហរណ៍ពណ៌លឿង ដែលភាគច្រើនសំនួរទាក់ទងនឹងវិទ្យាសាស្ត្រ ពណ៌បៃតងច្រើនទាក់ទងទៅនឹងសិល្បៈ និង វប្បធម៌ ពណ៌ស្វាយច្រើនទាក់ទងទៅនឹងសំនួរល្បងប្រាជ្ញា និង សំនួរទាក់ទងទៅនឹងពាក្យទំនៀមទំលាប់ ពណ៌ខៀវច្រើនទាក់ទងទៅនឹងសេដ្ឋវិទ្យា និង ចំនេះដឹងទូទៅ ហើយពណ៌ផ្កាឈូកច្រើនទាក់ទងទៅនឹងប្រវត្តិវិទ្យា និង ភូមិវិទ្យា។ ពេលដើរកូនដល់ត្រឹមពណ៌ណា ត្រូវឆ្លើយទៅនឹងសំនួរពណ៌នោះ។ សំនួរទាំងអស់មានជាង ២០០០ សំនួរ ត្រូវបានរៀបចំឡើង ដោយបុគ្គលិកអង្គការគ្រួសារថ្មី សហការជាមួយលោកសាស្ត្រាចារ្យ ម៉ិញ លីង៉ាន។

" អ្នកណាដឹង " ត្រូវបានចែកចាយទៅតាមមជ្ឈមណ្ឌលផ្សេងៗ នៃអង្គការគ្រួសារថ្មី ហើយជាទិសដៅរបស់យើងគឺ យើងមានបំនងចែកចាយដល់សាលាក្រីក្រនានានៅតាមជនបទ ក្នុងរាជាណាចក្រកម្ពុជា។ សាលាក្រីក្រនៅ

តាមជនបទទាំងនោះត្រូវធ្វើការស្នើសុំមកដល់អង្គការគ្រួសារថ្មីនៅភ្នំពេញ ហើយយើងនឹងធ្វើការពិនិត្យ និងសំរេចផ្ដល់អោយដោយឥតគិតថ្លៃ (ចំនួនមានកំនត់)។ ចំពោះអង្គការក្រៅរដ្ឋាភិបាល និង ស្ថាប័នផ្សេងៗ បើត្រូវការល្បែង"អ្នកណាដឹង " ដើម្បីចែកចាយដល់កន្លែងពាក់ព័ន្ធផ្សេងៗ នោះអង្គការគ្រួសារថ្មីនឹងលក់ជូនទៅតាមតំលៃមួយសមស្រប។

សូមទំនាក់ទំនងនៅអង្គការគ្រួសារថ្មី ដែលមានអាស័យដ្ឋាននៅផ្ទះលេខ ៤ ផ្លូវលេខ ២៥៧ សង្កាត់ទឹកល្អក់ទី១ ខ័ណ្ឌទួលគោករាជធានីភ្នំពេញ ទូរស័ព្ទលេខ : ០២៣ ៣៦៦ ១៨៤ រឺ ០២៣ ៨៨០ ៥០៣ និង ទូរសារលេខ : ០២៣ ៨៨២ ១១៣។



សិស្ស និង គ្រូ កំពុងរៀនភាសាខ្មែរ



ល្បែងអំពីវប្បធម៌សំរាប់ក្មេងកម្ពុជា